ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# លិខិតបទដ្ឋានគតិយុត្តសំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងផ្នែកផលិតកម្មសត្វនិងសុខភាពសត្វ ជលផល និងកសិ-ឧស្សាហកម្ម

| ល.រ | លេខលិខិត | ថ្ងៃខែលិខិត | របស់ | កម្មវត្ថុនៃលិខិត |
|---|---|---|---|---|
| ផ្នែកកសិ-ឧស្សាហកម្ម | | | | |
| ១ | លិខិតលេខ ៧៨ សសរ | ០៦-កញ្ញា-២០១៧ | រាជរដ្ឋាភិបាលកម្ពុជា | សេចក្តីសម្រេច ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលកិច្ចសន្យាផលិតកម្មកសិកម្ម |
| ផ្នែកជលផល | | | | |
| ២ | លិខិតលេខ ៥៤ អនក្រ.បក | ០២-មេសា-២០១៩ | រាជរដ្ឋាភិបាលកម្ពុជា | អនុក្រឹត្យ ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីរដ្ឋបាលជលផល |
| ផ្នែកផលិតកម្មសត្វ និងសុខភាពសត្វ | | | | |
| ៣ | លិខិតលេខ ៤១៤ ប្រក.កសក | ០១-តុលា-២០១៩ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រកាស ស្តីពី នីតិវិធីនៃការចេញលិខិតអនុញ្ញាត និងបទដ្ឋានបច្ចេកទេសនៃការនាំចូល ការនាំចេញ ការនាំឆ្លងកាត់ ការផលិត ការលាយផ្សំ ការវេចខ្ចប់ជាថ្មី ការធ្វើសន្និធិ ការផ្គត់ផ្គង់ចែកចាយ ការលក់ដុំលក់រាយ និងការដឹកជញ្ជូនបសុឱសថ |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៧៨ សសរ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
នាយកដ្ឋានកិច្ចការរដ្ឋបាល
ចូល
លេខ ២៦៥២
ថ្ងៃទី ១២ ... ១៧ ... ២០...
បញ្ជូន...

# សេចក្តីសម្រេច

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលកិច្ចសន្យាផលិតកម្មកសិកម្ម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ/.

- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្តីពីការដំឡើងនាយកដ្ឋានផលិតកម្មនិងបសុព្យាបាលទៅជាអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ
- បានឃើញអនុក្រឹត្យលេខ៣៦ អនក្រ.បក ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១១ ស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**ប្រការ១ ..**

សេចក្តីសម្រេចនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលកិច្ចសន្យាផលិតកម្មកសិកម្ម ដែលមានសមាសភាព ដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម **វេង សាខុន** | រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រធាន |
| ២- ឯកឧត្តម **ឌី ច័ន្ទ្រផល** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣- ឯកឧត្តម **សុខ ចិន្តាសោភា** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាអគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៤- ឯកឧត្តម **ម៉ុន អ៊ុយ** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៥- ឯកឧត្តម **ម៉ៅ ថូរ៉ា** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៦- ឯកឧត្តម **សរ សុវណ្ណា** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ | សមាជិក |
| ៧- ឯកឧត្តម **ចៅ ជេដ្ឋា** | រដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម | សមាជិក |
| ៨- ឯកឧត្តម **សៅ ជីវ័ន្ត** | រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៩- លោកជំទាវ **ចាន់ សុទ្ធាវី** | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ១០- ឯកឧត្តម **សុខុម គគវន្តមុនី** | រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ១១- ឯកឧត្តម **ជួន វាន** | រដ្ឋលេខាធិការក្រសួងឧស្សាហកម្មនិងសិប្បកម្ម | សមាជិក |
| ១២- ឯកឧត្តម **ហូ វិចិត្រ** | រដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល | សមាជិក |
| ១៣- ឯកឧត្តម **ផាន់ ផល្លា** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១៤- ឯកឧត្តម **សួខន ឫទ្ធីគុណា** | អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ១៥- ឯកឧត្តម លោកជំទាវអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត | | សមាជិក |
| ១៦- ឯកឧត្តម **កៅ ថាច** | អគ្គនាយកធនាគារអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១៧- ឯកឧត្តម **សុខ ស៊ីឡូ** | អគ្គលេខាធិការរងក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ | សមាជិក |

| | | |
|---|---|---|
| ១៨- បណ្ឌិត **គាន់ មុនីវណ្ណ** | អនុប្រធានសភាពាណិជ្ជកម្មកម្ពុជា | សមាជិក |
| ១៩- កញ្ញា **ឱម ស្រីពេជ្រ** | តំណាងសភាមុខរបរនិងមីក្រូសហគ្រាស | សមាជិក។ |

**ប្រការ២ .-**

គណៈកម្មាធិការសម្របសម្រួលកិច្ចសន្យាផលិតកម្មកសិកម្ម ត្រូវអនុវត្តភារកិច្ចដូចមានចែងក្នុងមាត្រា៧នៃអនុក្រឹត្យលេខ៣៦ អនក្រ.បក ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១១ ស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា។

**ប្រការ៣ .-**

ប្រធានគណៈកម្មាធិការសម្របសម្រួលកិច្ចសន្យាផលិតកម្មកសិកម្ម ត្រូវរៀបចំកិច្ចប្រជុំជាទៀងទាត់រៀងរាល់ដំណាច់ឆមាសនីមួយៗ។ ក្នុងករណីចាំបាច់ប្រធានអាចកោះប្រជុំវិសាមញ្ញបាន។ ក្នុងករណីប្រធានអវត្តមានឬមានធុរៈ អនុប្រធានដែលបានទទួលសិទ្ធិពីប្រធាន ត្រូវដឹកនាំការប្រជុំជំនួស។

ប្រធានគណៈកម្មាធិការអាចអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ មន្ត្រីជំនាញ អ្នកឯកទេសឬផ្នែកឯកជនចូលរួមប្រជុំពិគ្រោះ ពិភាក្សាយោបល់ និងសិក្សាស្រាវជ្រាវលើរាល់បញ្ហាទាំងឡាយដែលទាក់ទងនឹងការងាររបស់គណៈកម្មាធិការ។

**ប្រការ៤ .-**

គណៈកម្មាធិការនេះមានលេខាធិការដ្ឋានមួយជាជំនួយការ នៅនាយកដ្ឋានកសិ-ឧស្សាហកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដឹកនាំដោយប្រធាននាយកដ្ឋានកសិ-ឧស្សាហកម្ម។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការសម្របសម្រួលកិច្ចសន្យាផលិតកម្មកសិកម្ម។

**ប្រការ៥ .-**

គណៈកម្មាធិការនេះមានសិទ្ធិប្រើរូបសញ្ញានិងត្រារបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក្នុងកិច្ចដំណើរការការងារ។

**ប្រការ៦ .-**

ការចំណាយសម្រាប់កិច្ចដំណើរការរបស់គណៈកម្មាធិការ ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិ ក្នុងគម្រោងថវិការបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

គណៈកម្មាធិការនេះមានសិទ្ធិទទួលនិងចាត់ចែងប្រើប្រាស់តាមនីតិវិធីច្បាប់ជាធរមាននូវធនធាននិងមូលនិធិដែលបានមកពីប្រភពស្របច្បាប់ផ្សេងៗទៀត សម្រាប់កិច្ចដំណើរការការងារ។

**ប្រការ៧ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៨ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។/.

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

លេខ ១៩៩ ចល.កសក

បានចតចម្លងត្រឹមត្រូវតាមច្បាប់ដើម និងបញ្ជូនមក៖

- ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ "ដើម្បីជូនជ្រាប"
- ឯកឧត្តម លោក លោកស្រីប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត "ដើម្បីជ្រាប និងមុខការ"

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០១៧

**ត.ប រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**អគ្គលេខាធិការរង**

**ចាន់ ហេង**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៥៤ អនក្រ.បក

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ខុទ្ទកាល័យ
លេខ ១១៤៥
ថ្ងៃទី ០៤-០៤-១៩
បញ្ជូន

# អនុក្រឹត្យ
## ស្តីពី
## ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីរដ្ឋបាលជលផល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៧/០១៥ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា៦ មាត្រា៤១ មាត្រា៤២ មាត្រា៤៣ និងមាត្រា៩៥នៃច្បាប់ស្តីពីជលផលដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៦ ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារការកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ/

- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្ដីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្ដីពីការដំឡើងនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល ទៅជាអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីការបង្កើតឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីរដ្ឋបាលជលផលសម្រាប់បំពេញការងារអនុវត្តច្បាប់ស្តីពីជលផលនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យជលផល នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២ .-**

ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិនេះត្រូវបានអនុញ្ញាតឱ្យមន្ត្រីរដ្ឋបាលជលផល ដែលបម្រើការងារនៅរដ្ឋបាលជលផលនិងមន្ត្រីរដ្ឋបាលជលផលនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រើសម្រាប់៖

១- បំពេញការងារពាក់ព័ន្ធនឹងការគ្រប់គ្រងវិស័យជលផល។

២- បំពេញការងារពង្រឹងការអនុវត្តច្បាប់ ក្នុងប្រតិបត្តិការស្រាវជ្រាវ ស៊ើបអង្កេត ត្រួតពិនិត្យ ទប់ស្កាត់ និងបង្រ្កាបបទល្មើសជលផលគ្រប់ប្រភេទ។

៣- ចូលរួមពិធីបុណ្យមច្ឆជាតិឬពិធីប្រជុំផ្លូវការផ្សេងៗ។

៤- ចូលរួមសវនាការនៅតុលាការ។

## ជំពូកទី២
## ឯកសណ្ឋាន

**មាត្រា៣ .-**

ឯកសណ្ឋានរបស់មន្ត្រីរដ្ឋបាលជលផល មានដូចខាងក្រោម៖

១- សម្លៀកបំពាក់(អាវ ខោ និងសំពត់)។

២- មួក។

៣- ខ្សែក្រវាត់ ស្បែកជើង និងស្រោមជើង។

**មាត្រា៤ .-**

សម្លៀកបំពាក់របស់មន្ត្រីរដ្ឋបាលជលផល ត្រូវបានកំណត់យកប្រភេទសាច់ក្រណាត់ពណ៌កាគី ដូចខាងក្រោម៖ /ព/

១- អាវបុរស

អាវបុរសមាន៣ប្រភេទរួមមានៈ

១.១- អាវការងារ

អាវការងារមានដៃវែងឬខ្លីរបស់បុរស ករបើក ប៉ូលស្មាសងខាងសម្រាប់ទ្រនាប់សញ្ញាសម្គាល់សក្តិ មានហោប៉ៅចំនួន២ មានគម្របពីលើរាងស្លឹកពោធិ៍និងឡេវធម្មតាចំនួន៥គ្រាប់។

អាវការងារដៃវែងឬខ្លីរបស់បុរស ប្រើសម្រាប់បំពេញការងារពាក់ព័ន្ធនឹងការគ្រប់គ្រងវិស័យជលផល ចាប់ពីមន្ត្រីរដ្ឋបាលជលផលរហូតដល់ប្រធានរដ្ឋបាលជលផល។

១.២- អាវប្រតិបត្តិការ

អាវប្រតិបត្តិការដៃវែងរបស់បុរស មានពណ៌កាគី និងមានហោប៉ៅ(ស្បោង)ចំនួន៤។ ហោប៉ៅលើចំនួន២និងហោប៉ៅក្រោមចំនួន២។ ហោប៉ៅមានរាងជាស្បោង ដឺបមាត់ចំកណ្តាលរាងមូល និងមានគម្របបញ្ឆិតសន្ទះអណ្តាតចោះរន្ធនិងមានឡេវចំនួន១គ្រាប់បង្កប់។ អាវប្រតិបត្តិការដៃវែង មានដៃបំពង់ចុងដៃមានប៉ូលនិងមានឡេវចំនួន២គ្រាប់។

អាវប្រតិបត្តិការដៃវែងរបស់បុរស ប្រើសម្រាប់បំពេញការងារពង្រឹងការអនុវត្តច្បាប់ ក្នុងប្រតិបត្តិការស្រាវជ្រាវ ស៊ើបអង្កេត ត្រួតពិនិត្យ ទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផលគ្រប់ប្រភេទ ចាប់ពីមន្ត្រីរដ្ឋបាលជលផលរហូតដល់ថ្នាក់ប្រធានរដ្ឋបាលជលផល។

១.៣- អាវរ៉ាំរី

អាវរ៉ាំរីដៃវែងឬខ្លីរបស់បុរស មានពណ៌កាគី និងមានទម្រង់អាវធំ មានផែកក្រោយមួយ ករបើក ប៉ូលស្មាសងខាងសម្រាប់ធ្វើជាទ្រនាប់សញ្ញាសក្តិនិងមានភ្ជាប់ឡេវមាសចំនួន១គ្រាប់។ ផ្នែកខាងមុខមានហោប៉ៅចំនួន៤ មានគម្របពីលើរាងស្លាបជ្រឹងនិងឡេវភ្ជាប់គម្របពណ៌មាសចំនួន៤គ្រាប់។ ផ្នែកចំហៀងនៃចុងដៃអាវមានឡេវបញ្ចោតរូបព្រះរាជសង្ហារពណ៌មាសចំនួន៣គ្រាប់។

អាវរ៉ាំរីដៃវែងឬខ្លីរបស់បុរស ប្រើសម្រាប់ចូលរួមពិធីបុណ្យមច្ឆជាតិឬពិធីប្រជុំផ្លូវការផ្សេងៗ និងចូលរួមសវនាការនៅតុលាការ ចាប់ពីនាយរងសង្កាត់រដ្ឋបាលជលផលរហូតដល់ប្រធានរដ្ឋបាលជលផល។

២- ខោបុរស

ខោបុរសមាន២ប្រភេទរួមមានៈ

២.១- ខោការងារ

ខោការងារជើងវែងរបស់បុរស មានពណ៌កាគី ចង្កេះតង្កៀ និងមានជីបសងខាងខោចំនួន២។ ហោប៉ៅខោ មានចំនួន៤ នៅផ្នែកខាងក្រោយ មានហោប៉ៅចំនួន២ មានគម្របគ្របពីលើរាងស្លឹកពោធិ៍លើហោប៉ៅ និងមានឡេវធម្មតាចំនួន១គ្រាប់និងហោប៉ៅចំហៀងចំនួន២រាងបញ្ឆិត។

ខោការងារជើងវែងរបស់បុរស ប្រើសម្រាប់បំពេញការងារពាក់ព័ន្ធនឹងការគ្រប់គ្រងវិស័យជលផល ចូលរួមពិធីបុណ្យមច្ឆជាតិឬពិធីប្រជុំផ្លូវការផ្សេងៗ និងសវនាការនៅតុលាការ ចាប់ពីមន្ត្រីរដ្ឋបាលជលផលរហូតដល់ប្រធានរដ្ឋបាលជលផល។

២.២- ខោប្រតិបត្តិការ

ខោប្រតិបត្តិការជើងវែងរបស់បុរស មានពណ៌កាគី ចង្កេះលាត ជីបក្បាលជង្គង់នៅសងខាងនិងមានខ្សែរ៉ិត។ ហោប៉ៅខោ មានចំនួន៦ ហោប៉ៅក្រោយចំនួន២គម្របបញ្ឆិតសន្ទះអណ្តាតចោះរន្ធនិងមានឡេវចំនួន

១គ្រាប់ ហោប៉ៅចំហៀង មានចំនួន២រាងបញ្ឆិតនិងហោប៉ៅជង្គង់មានរាងជាស្បោងចំនួន២ មានជីបផ្ទត់២រាង ជ្រុង គម្របបញ្ឆិត មានសន្ទះអណ្ដាតចោះរន្ធនិងមានឡេវចំនួន២គ្រាប់។

ខោប្រតិបត្តិការជើងវែងរបស់បុរស ប្រើសម្រាប់បំពេញការងារពង្រឹងការអនុវត្តច្បាប់ ក្នុងប្រតិបត្តិការស្រាវជ្រាវ ស៊ើបអង្កេត ត្រួតពិនិត្យ ទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផលគ្រប់ប្រភេទ ចាប់ពីមន្ត្រីរដ្ឋបាលជលផលរហូតដល់ថ្នាក់ប្រធានរដ្ឋបាលជលផល។

៣- អាវនារី

អាវនារីមាន៣ប្រភេទរួមមាន៖

៣.១- អាវការងារ

អាវការងារដៃវែងឬខ្លីរបស់នារីមានពណ៌កាគី មានទម្រង់ដូចអាវការងាររបស់បុរសដែរ។

អាវការងារដៃវែងឬខ្លីរបស់នារី ប្រើសម្រាប់បំពេញការងារពាក់ព័ន្ធនឹងការគ្រប់គ្រងវិស័យជលផល ចូលរួមពិធីបុណ្យមច្ឆជាតិឬពិធីប្រជុំផ្លូវការផ្សេងៗ និងសវនាការនៅតុលាការ ចាប់ពីមន្ត្រីរដ្ឋបាលជលផលរហូតដល់ប្រធានរដ្ឋបាលជលផល។

៣.២- អាវប្រតិបត្តិការ

អាវប្រតិបត្តិការដៃវែងរបស់នារីមានទម្រង់ដូចអាវបំពេញប្រតិបត្តិការដៃវែងរបស់បុរសដែរ។

អាវប្រតិបត្តិការដៃវែងរបស់នារី ប្រើសម្រាប់បំពេញការងារពង្រឹងការអនុវត្តច្បាប់ ក្នុងប្រតិបត្តិការស្រាវជ្រាវ ស៊ើបអង្កេត ត្រួតពិនិត្យ ទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផលគ្រប់ប្រភេទ ចាប់ពីមន្ត្រីរដ្ឋបាលជលផលរហូតដល់ថ្នាក់ប្រធានរដ្ឋបាលជលផល។

៣.៣- អាវរ៉ាវី

អាវរ៉ាវីដៃវែងឬខ្លីរបស់នារីមានពណ៌កាគី និងមានទម្រង់អាវធំមានផែកក្រោយមួយដូចទម្រង់អាវរ៉ាវីបុរសដែរ។

អាវរ៉ាវីដៃវែងឬខ្លីរបស់នារី ប្រើសម្រាប់ចូលរួមពិធីបុណ្យមច្ឆជាតិឬពិធីប្រជុំផ្លូវការផ្សេងៗនិងសវនាការនៅតុលាការ ចាប់ពីនាយរងសង្កាត់រដ្ឋបាលជលផលរហូតដល់ប្រធានរដ្ឋបាលជលផល។

៤- សំពត់និងខោនារី

សំពត់និងខោរបស់នារីត្រូវបានកំណត់ដូចខាងក្រោម៖

៤.១- សំពត់ការងារ

សំពត់ការងាររបស់នារីមានពណ៌កាគី រាងបំពង់តចង្កេះ សម្រុងចុះក្រោមពាក់កណ្ដាលស្មងជើងផែកផ្នែកក្រោយចំកណ្ដាល និងមានរូតនៅចំហៀង។

សំពត់ការងាររបស់នារី ប្រើសម្រាប់ចូលរួមពិធីបុណ្យមច្ឆជាតិឬពិធីប្រជុំផ្លូវការផ្សេងៗនិងសវនាការនៅតុលាការ ចាប់ពីមន្ត្រីរដ្ឋបាលជលផលរហូតដល់ប្រធានរដ្ឋបាលជលផល។

៤.២- ខោការងារ

ខោការងារជើងវែងរបស់នារី មានទម្រង់ដូចខោការងាររបស់បុរសដែរ។

ខោការងារជើងវែងរបស់នារី ប្រើសម្រាប់បំពេញការងារពាក់ព័ន្ធនឹងការគ្រប់គ្រងវិស័យជលផល ចាប់ពីមន្ត្រីរដ្ឋបាលជលផលរហូតដល់ប្រធានរដ្ឋបាលជលផល។

៤.៣- ខោប្រតិបត្តិការ

ខោប្រតិបត្តិការជើងវែងរបស់នារី មានទម្រង់ដូចខោប្រតិបត្តិការជើងវែងរបស់បុរសដែរ។

ខោប្រតិបត្តិការជើងវែងរបស់នារី ប្រើសម្រាប់បំពេញការងារពង្រឹងការអនុវត្តច្បាប់ ក្នុងប្រតិបត្តិការស្រាវជ្រាវ ស៊ើបអង្កេត ត្រួតពិនិត្យ ទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផលគ្រប់ប្រភេទ ចាប់ពីមន្ត្រីរដ្ឋបាលជលផល រហូតដល់ថ្នាក់ប្រធានរដ្ឋបាលជលផល។

គំរូសម្លៀកបំពាក់របស់មន្ត្រីរដ្ឋបាលជលផល ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ។

**មាត្រា៥.-**

មួករបស់មន្ត្រីរដ្ឋបាលជលផលធ្វើអំពីសាច់ក្រណាត់ពណ៌កាគី មាន២ប្រភេទដូចខាងក្រោម៖

១. មួកកាស្កេត

មួកកាស្កេតត្រូវបានកំណត់៧ថ្នាក់:

១.១. ថ្នាក់ប្រធានរដ្ឋបាលជលផល

មួកកាស្កេតរបស់ប្រធានរដ្ឋបាលជលផល ផ្នែកខាងមុខលើកណ្តាប់វ័ណ្ឌ មានរូបព្រះរាជសង្ហារធ្វើអំពីលោហធាតុពណ៌មាសកម្ពស់៧៨មិល្លីម៉ែត្រនិងទទឹង៦៨មិល្លីម៉ែត្រ។

ផ្នែកខាងក្រោមរូបព្រះរាជសង្ហារ មានកណ្តាប់វ័ណ្ឌធ្វើអំពីក្រណាត់យឺតមានឆ្នូតពណ៌ខ្មៅព័ទ្ធជុំវិញ និងផ្នែកចុងក្បាំង មានឡេវរូបព្រះរាជសង្ហារពណ៌មាសចំនួន២គ្រាប់។ ផ្នែកខាងមុខកណ្តាប់វ័ណ្ឌ មានក្បាំងជំពណ៌ខ្មៅមានទម្រង់ជាស្លែងក្របីនៅក្រោមរូបព្រះរាជសង្ហារ។ ចុងសងខាងក្បាំងមួក មានឡេវរូបព្រះរាជសង្ហារចំនួន២គ្រាប់។ ផ្នែកខាងមុខក្រោមរូបព្រះរាជសង្ហារ មានក្បាច់ភ្ញីឱនពណ៌មាសនិងផ្នែកក្រោម មានខ្សែសយពណ៌មាស លើក្បាំងមួក មានប៉ាក់ក្បាច់ភ្ញីទេសឱនពណ៌មាសចំនួន៥សន្លឹកដែលមានទម្រង់ជាស្លែងក្របីដល់ជើងមួក។

១.២. ថ្នាក់អនុប្រធានរដ្ឋបាលជលផល

មួកកាស្កេតរបស់អនុប្រធានរដ្ឋបាលជលផលផ្នែកខាងមុខលើកណ្តាប់វ័ណ្ឌ មានរូបព្រះរាជសង្ហារធ្វើអំពីលោហធាតុពណ៌មាសកម្ពស់៧៨មិល្លីម៉ែត្រនិងទទឹង៦៨មិល្លីម៉ែត្រ។

ផ្នែកខាងក្រោមរូបព្រះរាជសង្ហារ មានកណ្តាប់វ័ណ្ឌធ្វើអំពីក្រណាត់យឺត មានឆ្នូតពណ៌ខ្មៅព័ទ្ធជុំវិញ និងផ្នែកចុងក្បាំង មានឡេវរូបព្រះរាជសង្ហារពណ៌មាសចំនួន២គ្រាប់។ ផ្នែកខាងមុខកណ្តាប់វ័ណ្ឌ មានក្បាំងជំពណ៌ខ្មៅមានទម្រង់ជាស្លែងក្របីនៅក្រោមរូបព្រះរាជសង្ហារ។ ចុងសងខាងក្បាំងមួក មានឡេវរូបព្រះរាជសង្ហារចំនួន២គ្រាប់។ ផ្នែកក្រោមមានខ្សែសយពណ៌មាសលើក្បាំងមួក មានប៉ាក់ក្បាច់ភ្ញីទេសឱនពណ៌មាសចំនួន៥សន្លឹក ដែលមានទម្រង់ជាស្លែងក្របីដល់ជើងមួក។

១.៣. ថ្នាក់ប្រធាននាយកដ្ឋាននិងនាយកវិទ្យាស្ថាន

មួកកាស្កេតរបស់ប្រធាននាយកដ្ឋាននិងនាយកវិទ្យាស្ថានផ្នែកខាងមុខលើកណ្តាប់វ័ណ្ឌ មានរូបព្រះរាជសង្ហារធ្វើអំពីលោហធាតុពណ៌មាសកម្ពស់៧៨មិល្លីម៉ែត្រនិងទទឹង៦៨មិល្លីម៉ែត្រ។

ផ្នែកខាងក្រោមរូបព្រះរាជសង្ហារមានកណ្តាប់វ័ណ្ឌធ្វើអំពីក្រណាត់យឺតមានឆ្នូតពណ៌ខ្មៅព័ទ្ធជុំវិញនិងផ្នែកចុងក្បាំង មានឡេវរូបព្រះរាជសង្ហារពណ៌មាសចំនួន២គ្រាប់។ ផ្នែកខាងមុខកណ្តាប់វ័ណ្ឌ មានក្បាំងជំពណ៌ខ្មៅមានទម្រង់ជាស្លែងក្របីនៅក្រោមរូបព្រះរាជសង្ហារ។ ចុងសងខាងក្បាំងមួកមានឡេវរូបព្រះរាជសង្ហារចំនួន២គ្រាប់។ ផ្នែកខាងមុខក្រោមរូបព្រះរាជសង្ហារមានខ្សែសយពណ៌មាស។ លើក្បាំងមួកមានប៉ាក់ក្បាច់ភ្ញីទេសឱនពណ៌មាសចំនួន៤សន្លឹកដែលមានទម្រង់ជាស្លែងក្របីដល់ជើងមួក។/

១.៤- ថ្នាក់អនុប្រធាននាយកដ្ឋាន នាយករងវិទ្យាស្ថាន នាយអធិការដ្ឋាន និងប្រធានមន្ទីរ

មួកកាស្កែតរបស់អនុប្រធាននាយកដ្ឋាន នាយករងវិទ្យាស្ថាន នាយអធិការដ្ឋាន និងប្រធានមន្ទីរ ផ្នែកខាងមុខលើកណ្តាប់វ័ណ្ឌ មានរូបព្រះរាជសង្ហារធ្វើអំពីលោហធាតុពណ៌មាសកម្ពស់៧៨មិល្លីម៉ែត្រនិងទទឹង ៦៨មិល្លីម៉ែត្រ។

ផ្នែកខាងក្រោមរូបព្រះរាជសង្ហារ មានកណ្តាប់វ័ណ្ឌធ្វើអំពីក្រណាត់យឺតមានឆ្នូតពណ៌ខ្មៅព័ទ្ធជុំវិញនិង ផ្នែកចុងក្បាំង មានឡេវរូបព្រះរាជសង្ហារពណ៌មាសចំនួន២គ្រាប់។ ផ្នែកខាងមុខកណ្តាប់វ័ណ្ឌមានក្បាំងធំពណ៌ ខ្មៅមានទម្រង់ជាស្លែងក្របីនៅក្រោមរូបព្រះរាជសង្ហារ។ ចុងសងខាងក្បាំងមួកមានឡេវរូបព្រះរាជសង្ហារចំនួន ២គ្រាប់។ ផ្នែកខាងមុខក្រោមរូបព្រះរាជសង្ហារមានខ្សែសយពណ៌មាស។ លើក្បាំងមួកមានប៉ាក់ក្បាច់ភ្ញីទេសឌិន ពណ៌មាសចំនួន៣សន្លឹកដែលមានទម្រង់ជាស្លែងក្របីដល់ជើងមួក។

១.៥- ថ្នាក់ប្រធានការិយាល័យថ្នាក់កណ្តាល ប្រធានមជ្ឈមណ្ឌល នាយរងអធិការដ្ឋាន អនុប្រធាន មន្ទីរ និងនាយខណ្ឌរដ្ឋបាលជលផល

មួកកាស្កែតរបស់ប្រធានការិយាល័យថ្នាក់កណ្តាល ប្រធានមជ្ឈមណ្ឌល នាយរងអធិការដ្ឋាន អនុប្រធាន មន្ទីរ និងនាយខណ្ឌរដ្ឋបាលជលផល ផ្នែកខាងមុខលើកណ្តាប់វ័ណ្ឌ មានរូបព្រះរាជសង្ហារធ្វើអំពីលោហធាតុពណ៌មាស កម្ពស់៧៨មិល្លីម៉ែត្រនិងទទឹង៦៨មិល្លីម៉ែត្រ។

ផ្នែកខាងក្រោមរូបព្រះរាជសង្ហារមានកណ្តាប់វ័ណ្ឌធ្វើពីក្រណាត់យឺតមានឆ្នូតពណ៌ខ្មៅព័ទ្ធជុំវិញនិង ផ្នែកចុងក្បាំង មានឡេវរូបព្រះរាជសង្ហារពណ៌មាសចំនួន២គ្រាប់។ ផ្នែកខាងមុខកណ្តាប់វ័ណ្ឌមានក្បាំងធំពណ៌ ខ្មៅមានទម្រង់ជាស្លែងក្របីនៅក្រោមរូបព្រះរាជសង្ហារ។ ចុងសងខាងក្បាំងមួកមានឡេវរូបព្រះរាជសង្ហារចំនួន២ គ្រាប់និងនៅរឹមក្បាំងមួក មានខ្សែសយពណ៌មាសព័ទ្ធជុំវិញ។

១.៦- ថ្នាក់អនុប្រធានការិយាល័យថ្នាក់កណ្តាល អនុប្រធានមជ្ឈមណ្ឌល នាយរងខណ្ឌរដ្ឋបាល ជលផល នាយ នាយរងផ្នែករដ្ឋបាលជលផល និងនាយ នាយរងសង្កាត់រដ្ឋបាលជលផល

មួកកាស្កែតរបស់អនុប្រធានការិយាល័យថ្នាក់កណ្តាលអនុប្រធានមជ្ឈមណ្ឌល នាយរងខណ្ឌរដ្ឋបាល ជលផល នាយ នាយរងផ្នែករដ្ឋបាលជលផល និងនាយ នាយរងសង្កាត់រដ្ឋបាលជលផល ផ្នែកខាងមុខលើ កណ្តាប់វ័ណ្ឌ មានរូបព្រះរាជសង្ហារធ្វើអំពីលោហធាតុពណ៌មាសកម្ពស់៧៨មិល្លីម៉ែត្រនិងទទឹង៦៨មិល្លីម៉ែត្រ។

ផ្នែកខាងក្រោមរូបព្រះរាជសង្ហារមានកណ្តាប់វ័ណ្ឌធ្វើពីក្រណាត់យឺតមានឆ្នូតពណ៌ខ្មៅព័ទ្ធជុំវិញនិង ផ្នែកចុងក្បាំង មានឡេវរូបព្រះរាជសង្ហារពណ៌មាសចំនួន២គ្រាប់។ ផ្នែកខាងមុខកណ្តាប់វ័ណ្ឌមានក្បាំងធំពណ៌ ខ្មៅមានទម្រង់ជាស្លែងក្របីនៅក្រោមរូបព្រះរាជសង្ហារ។ ចុងសងខាងក្បាំងមួកមានឡេវរូបព្រះរាជសង្ហារចំនួន ២គ្រាប់និងនៅរឹមក្បាំងមួកមានខ្សែសយពណ៌ប្រាក់ព័ទ្ធជុំវិញ។

១.៧- ថ្នាក់មន្ត្រី

មួកកាស្កែតរបស់មន្ត្រីរដ្ឋបាលជលផលផ្នែកខាងមុខលើកណ្តាប់វ័ណ្ឌមានរូបព្រះរាជសង្ហារធ្វើអំពី លោហធាតុពណ៌មាសកម្ពស់៧៨មិល្លីម៉ែត្រនិងទទឹង៦៨មិល្លីម៉ែត្រ។

ផ្នែកខាងក្រោមរូបព្រះរាជសង្ហារមានកណ្តាប់វ័ណ្ឌធ្វើពីក្រណាត់យឺតមានឆ្នូតពណ៌ខ្មៅព័ទ្ធជុំវិញ និង ផ្នែកចុងក្បាំងមានឡេវរូបព្រះរាជសង្ហារពណ៌មាសចំនួន២គ្រាប់។ ផ្នែកខាងមុខកណ្តាប់វ័ណ្ឌមានក្បាំងធំពណ៌ ខ្មៅមានទម្រង់ជាស្លែងក្របីនៅក្រោមរូបព្រះរាជសង្ហារ។ ចុងសងខាងក្បាំងមួកមានឡេវរូបព្រះរាជសង្ហារចំនួន ២គ្រាប់។

មួកកាស្កែតរបស់មន្ត្រីរដ្ឋបាលជលផល ប្រើសម្រាប់ចូលរួមសវនាការនៅតុលាការនិងចូលរួមពិធី ផ្លូវការផ្សេងៗ។

២- មួកកន្ទឹប

មួកកន្ទឹបត្រូវបានកំណត់៧ថ្នាក់៖

២.១- ថ្នាក់ប្រធានរដ្ឋបាលជលផល

មួកកន្ទឹបរបស់ប្រធានរដ្ឋបាលជលផលផ្នែកខាងមុខលើកណ្តាប់វ័ណ្ណមានរូបព្រះរាជសង្ហារធ្វើអំពីលោហធាតុពណ៌មាសកម្ពស់៥០មិល្លីម៉ែត្រនិងទទឹង៤០មិល្លីម៉ែត្រ។ ផ្នែកខាងក្រោយជើងមួកមានភ្ជាប់ក្រណាត់យឺត។ ផ្នែកខាងក្រោមរូបព្រះរាជសង្ហារមានកណ្តាប់វ័ណ្ណធ្វើពីក្រណាត់យឺតមានធ្មួតពណ៌ខ្មៅព័ទ្ធជុំវិញនិងផ្នែកចុងក្បាំង មានឡេវរូបព្រះរាជសង្ហារពណ៌មាសចំនួន២គ្រាប់។ ផ្នែកខាងមុខកណ្តាប់វ័ណ្ណមានក្បាំងធំពណ៌ខ្មៅមានទម្រង់ជាស្នែងក្របីនៅក្រោមរូបព្រះរាជសង្ហារ។ ចុងសងខាងក្បាំងមួកមានឡេវរូបព្រះរាជសង្ហារចំនួន២គ្រាប់។ ផ្នែកខាងមុខក្រោមរូបព្រះរាជសង្ហារ មានក្បាច់ភ្ញីឱនពណ៌មាសនិងផ្នែកក្រោម មានខ្សែសយពណ៌មាសលើក្បាំងមួក មានប៉ាក់ក្បាច់ភ្ញីទេសឱនពណ៌មាសចំនួន៥សន្លឹកដែលមានទម្រង់ជាស្នែងក្របីដល់ជើងមួក។

២.២- ថ្នាក់អនុប្រធានរដ្ឋបាលជលផល

មួកកន្ទឹបរបស់អនុប្រធានរដ្ឋបាលជលផលផ្នែកខាងមុខលើកណ្តាប់វ័ណ្ណមានរូបព្រះរាជសង្ហារធ្វើអំពីលោហធាតុពណ៌មាសកម្ពស់៥០មិល្លីម៉ែត្រនិងទទឹង៤០មិល្លីម៉ែត្រ។ ផ្នែកខាងក្រោយជើងមួកមានភ្ជាប់ក្រណាត់យឺត។ ផ្នែកខាងក្រោមរូបព្រះរាជសង្ហារមានកណ្តាប់វ័ណ្ណធ្វើអំពីក្រណាត់យឺតមានធ្មួតពណ៌ខ្មៅព័ទ្ធជុំវិញនិងផ្នែកចុងក្បាំង មានឡេវរូបព្រះរាជសង្ហារពណ៌មាសចំនួន២គ្រាប់។ ផ្នែកខាងមុខកណ្តាប់វ័ណ្ណមានក្បាំងធំពណ៌ខ្មៅមានទម្រង់ជាស្នែងក្របីនៅក្រោមរូបព្រះរាជសង្ហារ។ ចុងសងខាងក្បាំងមួក មានឡេវរូបព្រះរាជសង្ហារចំនួន២គ្រាប់។ ផ្នែកក្រោមមានខ្សែសយពណ៌មាសលើក្បាំងមួកមានប៉ាក់ក្បាច់ភ្ញីទេសឱនពណ៌មាសចំនួន៥សន្លឹកដែលមានទម្រង់ជាស្នែងក្របីដល់ជើងមួក។

២.៣- ថ្នាក់ប្រធាននាយកដ្ឋាននិងនាយកវិទ្យាស្ថាន

មួកកន្ទឹបរបស់ប្រធាននាយកដ្ឋាននិងនាយកវិទ្យាស្ថានផ្នែកខាងមុខលើកណ្តាប់វ័ណ្ណ មានរូបព្រះរាជសង្ហារធ្វើអំពីលោហធាតុពណ៌មាសកម្ពស់៥០មិល្លីម៉ែត្រនិងទទឹង៤០មិល្លីម៉ែត្រ។ ផ្នែកខាងក្រោយជើងមួកមានភ្ជាប់ក្រណាត់យឺត។ ផ្នែកខាងក្រោមរូបព្រះរាជសង្ហារមានកណ្តាប់វ័ណ្ណធ្វើពីក្រណាត់យឺត មានធ្មួតពណ៌ខ្មៅព័ទ្ធជុំវិញនិងផ្នែកចុងក្បាំង មានឡេវរូបព្រះរាជសង្ហារពណ៌មាសចំនួន២គ្រាប់។ ផ្នែកខាងមុខកណ្តាប់វ័ណ្ណមានក្បាំងធំពណ៌ខ្មៅមានទម្រង់ជាស្នែងក្របីនៅក្រោមរូបព្រះរាជសង្ហារ។ ចុងសងខាងក្បាំងមួកមានឡេវរូបព្រះរាជសង្ហារចំនួន២គ្រាប់។ ផ្នែកខាងមុខក្រោមរូបព្រះរាជសង្ហារមានខ្សែសយពណ៌មាសលើក្បាំងមួក មានប៉ាក់ក្បាច់ភ្ញីទេសឱនពណ៌មាសចំនួន៤សន្លឹកដែលមានទម្រង់ជាស្នែងក្របីដល់ជើងមួក។

២.៤- ថ្នាក់អនុប្រធាននាយកដ្ឋាន នាយករងវិទ្យាស្ថាន នាយអធិការដ្ឋាន និងប្រធានមន្ទីរ

មួកកន្ទឹបរបស់អនុប្រធាននាយកដ្ឋាន នាយករងវិទ្យាស្ថាន នាយអធិការដ្ឋាន និងប្រធានមន្ទីរ ផ្នែកខាងមុខលើកណ្តាប់វ័ណ្ណ មានរូបព្រះរាជសង្ហារធ្វើអំពីលោហធាតុពណ៌មាសកម្ពស់៥០មិល្លីម៉ែត្រនិងទទឹង៤០មិល្លីម៉ែត្រ។ ផ្នែកខាងក្រោយជើងមួកមានភ្ជាប់ក្រណាត់យឺត។ ផ្នែកខាងក្រោមរូបព្រះរាជសង្ហារមានកណ្តាប់វ័ណ្ណធ្វើអំពីក្រណាត់យឺតមានធ្មួតពណ៌ខ្មៅព័ទ្ធជុំវិញនិងផ្នែកចុងក្បាំង មានឡេវរូបព្រះរាជសង្ហារពណ៌មាសចំនួន២គ្រាប់។ ផ្នែកខាងមុខកណ្តាប់វ័ណ្ណមានក្បាំងធំពណ៌ខ្មៅមានទម្រង់ជាស្នែងក្របីនៅក្រោមរូបព្រះរាជសង្ហារ។ ចុងសងខាងក្បាំងមួកមានឡេវរូបព្រះរាជសង្ហារចំនួន២គ្រាប់។ ផ្នែកខាងមុខក្រោមរូបព្រះរាជសង្ហារមានខ្សែសយពណ៌មាស លើក្បាំងមួក មានប៉ាក់ក្បាច់ភ្ញីទេសឱនពណ៌មាសចំនួន៣សន្លឹកដែលមានទម្រង់ជាស្នែងក្របីដល់ជើងមួក។

២.៥- ថ្នាក់ប្រធានការិយាល័យថ្នាក់កណ្ដាល ប្រធានមជ្ឈមណ្ឌល នាយរងអធិការដ្ឋាន អនុប្រធានមន្ទីរ និងនាយខណ្ឌរដ្ឋបាលជលផល

មួកកន្ទឹបរបស់ប្រធានការិយាល័យថ្នាក់កណ្ដាល ប្រធានមជ្ឈមណ្ឌល នាយរងអធិការដ្ឋាន អនុប្រធានមន្ទីរ និងនាយខណ្ឌរដ្ឋបាលជលផល ផ្នែកខាងមុខលើកណ្ដាប់វ័ណ្ឌ មានរូបព្រះរាជសង្ហារធ្វើពីលោហធាតុពណ៌មាសកម្ពស់៥០មិល្លីម៉ែត្រនិងទទឹង៤០មិល្លីម៉ែត្រ។

ផ្នែកខាងក្រោយជើងមួកមានភ្ជាប់ក្រណាត់យឺត។ ផ្នែកខាងក្រោមរូបព្រះរាជសង្ហារមានកណ្ដាប់វ័ណ្ឌធ្វើពីក្រណាត់យឺតមានឆ្នូតពណ៌ខ្មៅព័ទ្ធជុំវិញនិងផ្នែកចុងក្បាំង មានឡេវរូបព្រះរាជសង្ហារពណ៌មាសចំនួន២គ្រាប់។ ផ្នែកខាងមុខកណ្ដាប់វ័ណ្ឌ មានក្បាំងជ័ពណ៌ខ្មៅមានទម្រង់ជាស្លែងក្របីនៅក្រោមរូបព្រះរាជសង្ហារ។ ចុងសងខាងក្បាំងមួកមានឡេវរូបព្រះរាជសង្ហារចំនួន២គ្រាប់និងនៅមែកក្បាំងមួកមានខ្សែសយ ពណ៌មាសព័ទ្ធជុំវិញ។

២.៦- ថ្នាក់អនុប្រធានការិយាល័យថ្នាក់កណ្ដាល អនុប្រធានមជ្ឈមណ្ឌល នាយរងខណ្ឌរដ្ឋបាលជលផល នាយ នាយរងផ្នែករដ្ឋបាលជលផល និងនាយ នាយរងសង្កាត់រដ្ឋបាលជលផល

មួកកន្ទឹបរបស់អនុប្រធានការិយាល័យថ្នាក់កណ្ដាល អនុប្រធានមជ្ឈមណ្ឌល នាយរងខណ្ឌរដ្ឋបាលជលផល នាយ នាយរងផ្នែករដ្ឋបាលជលផល និងនាយ នាយរងសង្កាត់រដ្ឋបាលជលផល ផ្នែកខាងមុខលើកណ្ដាប់វ័ណ្ឌ មានរូបព្រះរាជសង្ហារធ្វើពីលោហធាតុពណ៌មាសកម្ពស់៥០មិល្លីម៉ែត្រនិងទទឹង៤០មិល្លីម៉ែត្រ។ ផ្នែកខាងក្រោយជើងមួក មានភ្ជាប់ក្រណាត់យឺត។ ផ្នែកខាងក្រោមរូបព្រះរាជសង្ហារ មានកណ្ដាប់វ័ណ្ឌធ្វើអំពីក្រណាត់យឺតមានឆ្នូតពណ៌ខ្មៅព័ទ្ធជុំវិញនិងផ្នែកចុងក្បាំង មានឡេវរូបព្រះរាជសង្ហារពណ៌មាសចំនួន២គ្រាប់។ ផ្នែកខាងមុខកណ្ដាប់វ័ណ្ឌមានក្បាំងជ័ពណ៌ខ្មៅមានទម្រង់ជាស្លែងក្របីនៅក្រោមរូបព្រះរាជសង្ហារ។ ចុងសងខាងក្បាំងមួក មានឡេវរូបព្រះរាជសង្ហារចំនួន២គ្រាប់និងនៅមែកក្បាំងមួកមានខ្សែសយពណ៌ប្រាក់ព័ទ្ធជុំវិញ។

២.៧- ថ្នាក់មន្ត្រី

មួកកន្ទឹបរបស់មន្ត្រីរដ្ឋបាលជលផលផ្នែកខាងមុខលើកណ្ដាប់វ័ណ្ឌ មានរូបព្រះរាជសង្ហារធ្វើអំពីលោហធាតុ ពណ៌មាសកម្ពស់៥០មិល្លីម៉ែត្រនិងទទឹង៤០មិល្លីម៉ែត្រ។ ផ្នែកខាងក្រោយជើងមួកមានភ្ជាប់ក្រណាត់យឺត។

ផ្នែកខាងក្រោមរូបព្រះរាជសង្ហារមានកណ្ដាប់វ័ណ្ឌធ្វើពីក្រណាត់យឺតមានឆ្នូតពណ៌ខ្មៅព័ទ្ធជុំវិញ និងផ្នែកចុងក្បាំង មានឡេវរូបព្រះរាជសង្ហារពណ៌មាសចំនួន២គ្រាប់។ ផ្នែកខាងមុខកណ្ដាប់វ័ណ្ឌមានក្បាំងជ័ពណ៌ខ្មៅមានទម្រង់ជាស្លែងក្របីនៅក្រោមរូបព្រះរាជសង្ហារ។ ចុងសងខាងក្បាំងមួកមានឡេវរូបព្រះរាជសង្ហារចំនួន២គ្រាប់។

មួកកន្ទឹបរបស់មន្ត្រីរដ្ឋបាលជលផល ប្រើសម្រាប់បំពេញបេសកកម្មពាក់ព័ន្ធនឹងការគ្រប់គ្រងវិស័យជលផលនិងបំពេញប្រតិបត្តិការ ស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផល។

គំរូមួករបស់មន្ត្រីរដ្ឋបាលជលផលត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។

**មាត្រា៦ .-**

ខ្សែក្រវាត់ ស្បែកជើង និងស្រោមជើងមន្ត្រីរដ្ឋបាលជលផល ត្រូវបានកំណត់ដូចខាងក្រោម៖

១- ចំពោះបុរស

១.១- ខ្សែក្រវាត់

ខ្សែក្រវាត់របស់បុរសមានពណ៌ខ្មៅ ក្បាលខ្សែក្រវាត់មានពណ៌មាសឬពណ៌ប្រាក់ ទំហំបណ្ដោយ៦៥មិល្លីម៉ែត្រនិងទទឹង៣៨មិល្លីម៉ែត្រ។ ផ្នែកក្បាលខ្សែក្រវាត់មាននិមិត្តសញ្ញារដ្ឋបាលជលផលនៅចំកណ្ដាល។

ក្បាលខ្សែក្រវាត់របស់បុរសពណ៌មាស ប្រើចាប់ពីនាយរងសង្កាត់រដ្ឋបាលជលផលរហូតដល់ប្រធានរដ្ឋបាលជលផល។

ក្បាលខ្សែក្រវាត់របស់បុរសពណ៌ប្រាក់ ប្រើសម្រាប់មន្ត្រីរដ្ឋបាលជលផល។

១.២- ស្បែកជើង

ស្បែកជើងរបស់បុរសមាន២ប្រភេទរួមមាន៖

- ស្បែកជើងឃ្លុបកខ្លីឬកវែងបុរសមានខ្សែចងធ្វើពីស្បែកពណ៌ខ្មៅ
- ស្បែកជើងផ្ទាត់

១.៣- ស្រោមជើង

ស្រោមជើងរបស់បុរសមានពណ៌ខ្មៅ។

ខ្សែក្រវាត់ ស្បែកជើង និងស្រោមជើងរបស់បុរស ប្រើចាប់ពីថ្នាក់មន្ត្រីរដ្ឋបាលជលផលរហូតដល់ប្រធានរដ្ឋបាលជលផល សម្រាប់បំពេញបេសកកម្មពាក់ព័ន្ធនឹងការគ្រប់គ្រងវិស័យជលផល បំពេញប្រតិបត្តិការស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផល ចូលរួមសវនាការនៅតុលាការ និងចូលរួមពិធីផ្លូវការផ្សេងៗ។

២- ចំពោះនារី

២.១- ខ្សែក្រវាត់

ខ្សែក្រវាត់របស់នារីមានពណ៌ខ្មៅ ក្បាលខ្សែក្រវាត់មានពណ៌មាសឬពណ៌ប្រាក់ និងមានទម្រង់ដូចខ្សែក្រវាត់របស់បុរសដែរ។

ការប្រើប្រាស់ក្បាលខ្សែក្រវាត់ពណ៌មាសឬពណ៌ប្រាក់ ក៏អនុវត្តដូចការប្រើប្រាស់ខ្សែក្រវាត់របស់បុរសដែរ។

២.២- ស្បែកជើង

ស្បែកជើងរបស់នារីមាន២ប្រភេទរួមមាន៖

- ស្បែកជើងឃ្លុបស្បែកពណ៌ខ្មៅមានកែងស្មើឬកែងចោត
- ស្បែកជើងផ្ទាត់

២.៣- ស្រោមជើង

ស្រោមជើងរបស់នារីមានពណ៌ខ្មៅ។

គំរូខ្សែក្រវាត់ ស្បែកជើង និងស្រោមជើងរបស់មន្ត្រីរដ្ឋបាលជលផល ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៣នៃអនុក្រឹត្យនេះ។

## **ជំពូកទី៣**
## **សញ្ញាសម្គាល់**

**មាត្រា៧.-**

សញ្ញាសម្គាល់រដ្ឋបាលជលផលត្រូវបានកំណត់ដូចខាងក្រោម៖

១- និមិត្តសញ្ញារដ្ឋបាលជលផល

និមិត្តសញ្ញារដ្ឋបាលជលផលមានលក្ខណៈនិងភិនភាគដូចតទៅ៖

- វណ្ឌខាងក្រៅផ្នែកខាងលើមានកន្ទុយនាគរាជពីរព័ទ្ធគ្នាជាក្បាច់ភ្ញីពណ៌មាស
- វណ្ឌខាងក្រៅផ្នែកខាងក្រោមមានផ្ទៃពណ៌ក្រហមរំលេចដោយតួអក្សរ"**ជលផលកម្ពុជា**" ពណ៌សនិងផ្នែកចុងសងខាងមានពីរផ្នត់
- វណ្ឌខាងក្រៅផ្នែកសងខាងមានខ្លួននិងក្បាលនាគរាជចំនួន២ពណ៌មាសបែរមុខចេញក្រៅ
- ផ្ទៃខាងក្នុង៖

- ផ្នែកលើមានពណ៌ផ្ទៃមេឃរលេចទៅដោយរូបត្រីចំនួន២ពណ៌ស និងរូបបង្កង១ក្បាលនៅចំកណ្តាលដែលមានពណ៌មាស។
- ផ្នែកកណ្តាលមានព្រៃលិចទឹកនិងព្រៃកោងកាងមានពណ៌បៃតងខ្ចី
- ផ្នែកក្រោមមានរូបទឹករលកចំនួន៧ ពណ៌ខៀវទឹកប៊ិចព័ទ្ធដោយទឹកសមុទ្រពណ៌ផ្ទៃមេឃដែលរលេចដោយជាយពណ៌ស។

**១.១- និមិត្តសញ្ញារដ្ឋបាលជលផលសម្រាប់ពាក់លើចុងកអាវទាំងសងខាង**

និមិត្តសញ្ញាធ្វើអំពីលោហធាតុរាងមូលសំប៉ែតមានអង្កត់ផ្ចិត៣០មិល្លីម៉ែត្រ ជានិមិត្តសញ្ញារបស់រដ្ឋបាលជលផល។

និមិត្តសញ្ញាធ្វើអំពីលោហធាតុសម្រាប់ខ្ទាស់លើកអាវទាំងសងខាង ប្រើចាប់ពីមន្ត្រីរដ្ឋបាលជលផលរហូតដល់ប្រធានរដ្ឋបាលជលផលសម្រាប់បំពេញបេសកកម្មពាក់ព័ន្ធនឹងការគ្រប់គ្រងវិស័យជលផល បំពេញប្រតិបត្តិការស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផល ចូលរួមសវនាការនៅតុលាការ និងចូលរួមពិធីផ្លូវការផ្សេងៗ។

**១.២- និមិត្តសញ្ញារដ្ឋបាលជលផលសម្រាប់ដេរភ្ជាប់លើដើមដៃអាវខាងស្តាំ**

និមិត្តសញ្ញាធ្វើអំពីសាច់ក្រណាត់ដែលមានអង្កត់ផ្ចិត៧០មិល្លីម៉ែត្រ សម្រាប់ដេរភ្ជាប់លើដើមដៃអាវខាងស្តាំក្រោមថ្នេរស្មា៥០មិល្លីម៉ែត្រដោយកំណត់យកត្លីជាចំណុចកណ្តាល។

និមិត្តសញ្ញាសម្រាប់ដេរភ្ជាប់លើដើមដៃអាវខាងស្តាំ ប្រើចាប់ពីមន្ត្រីរដ្ឋបាលជលផលរហូតដល់ប្រធានរដ្ឋបាលជលផលសម្រាប់បំពេញបេសកកម្មពាក់ព័ន្ធនឹងការគ្រប់គ្រងវិស័យជលផល បំពេញប្រតិបត្តិការស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផល ចូលរួមសវនាការនៅតុលាការ និងចូលរួមពិធីផ្លូវការផ្សេងៗ។

**២- សញ្ញាសម្គាល់ត្រីគល់រាំងសម្រាប់ដេរភ្ជាប់លើដើមដៃអាវខាងឆ្វេង៖**

សញ្ញាសម្គាល់ត្រីគល់រាំងធ្វើពីក្រណាត់រាងមូលមានអង្កត់ផ្ចិតទំហំ៧០មិល្លីម៉ែត្រ ស៊ុមព័ទ្ធជុំវិញផ្ទៃពណ៌ទឹកប៊ិច។ ផ្ទៃខាងក្នុងពណ៌ផ្ទៃមេឃ មានរូប"**ត្រីគល់រាំង**"មួយក្បាលពណ៌មាស។ ខាងលើរូបត្រីក្នុងរង្វង់មានសរសេរអក្សរ "**ត្រីគល់រាំង**"ពណ៌មាស។ ផ្នែកក្រៅរង្វង់រូបត្រីនិងអក្សរត្រីគល់រាំង មានរង្វង់មួយទៀតដែលមានអង្កត់ផ្ចិតទំហំ១០០មិល្លីម៉ែត្រ និងនៅរឹមមានខ្សែសយពណ៌សព័ទ្ធជុំវិញ។ ផ្នែកក្រោមរង្វង់មានសរសេរអក្សរពណ៌មាស"**រដ្ឋបាលជលផល**" និងផ្នែកលើរង្វង់មានសរសេរអក្សរពណ៌មាស "**ព្រះរាជាណាចក្រកម្ពុជា**"។

សញ្ញាសម្គាល់ត្រីគល់រាំងសម្រាប់ដេរភ្ជាប់នៅលើដើមដៃអាវខាងឆ្វេងមានប្រវែង៥០មិល្លីម៉ែត្រពីថ្នេរស្មាអាវ ប្រើចាប់ពីមន្ត្រីរដ្ឋបាលជលផលរហូតដល់ប្រធានរដ្ឋបាលជលផលសម្រាប់បំពេញបេសកកម្មពាក់ព័ន្ធនឹងការគ្រប់គ្រងវិស័យជលផល បំពេញប្រតិបត្តិការស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផល ចូលរួមសវនាការនៅតុលាការ និងចូលរួមពិធីផ្លូវការផ្សេងៗ។

**៣- ស្លាកសម្គាល់ឈ្មោះ**

ស្លាកសម្គាល់ឈ្មោះរបស់មន្ត្រីរដ្ឋបាលជលផលធ្វើពីជ័ររឹងមានរាងចតុកោណកែង មានស៊ុមឆ្នូតព័ទ្ធជុំវិញពណ៌មាសឬពណ៌ប្រាក់មានបណ្តោយប្រវែង១០០មិល្លីម៉ែត្រនិងទទឹងប្រវែង២០មិល្លីម៉ែត្រ និងកម្រាស់២មិល្លីម៉ែត្រ មានពណ៌ផ្ទៃទឹកសមុទ្រ។ ផ្នែកខាងឆ្វេងមាននិមិត្តសញ្ញារដ្ឋបាលជលផលកម្ពស់១៥មិល្លីម៉ែត្រនិងទទឹង១២មិល្លីម៉ែត្រ មានបន្ទាត់ឈរខណ្ឌចែករវាងនិមិត្តសញ្ញារដ្ឋបាលជលផល និងឈ្មោះមន្ត្រី រដ្ឋបាលជលផល។ ផ្នែកខាងស្តាំជួរខាងលើសរសេរឈ្មោះមន្ត្រីរដ្ឋបាលជលផល ជួរកណ្តាលសរសេរតួនាទីនិងអត្តលេខរបស់មន្ត្រីរដ្ឋបាលជលផល(លេខខ្មែរ)ដែលមានពណ៌មាសឬពណ៌ប្រាក់។/.

ស្លាកសម្គាល់ឈ្មោះរបស់មន្ត្រីរដ្ឋបាលជលផលប្រើសម្រាប់ខ្ទាស់នៅផ្នែកខាងលើហោប៉ៅអាវខាងស្តាំ។

ស្លាកសម្គាល់ឈ្មោះពណ៌មាស ប្រើចាប់ពីនាយរងសង្កាត់រដ្ឋបាលជលផលរហូតដល់ប្រធានរដ្ឋបាលជលផល។

ស្លាកសម្គាល់ឈ្មោះពណ៌ប្រាក់ ប្រើសម្រាប់មន្ត្រីរដ្ឋបាលជលផល។

ស្លាកសម្គាល់ឈ្មោះពណ៌មាសឬពណ៌ប្រាក់ ប្រើសម្រាប់បំពេញបេសកកម្មពាក់ព័ន្ធនឹងការគ្រប់គ្រងវិស័យជលផល បំពេញប្រតិបត្តិការស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផល ចូលរួមសវនាការនៅតុលាការ និងចូលរួមពិធីផ្លូវការផ្សេងៗ។

៤- សញ្ញាសម្គាល់សម្រាប់ព្យួរលើខ្សែគម្របហោប៉ៅអាវខាងស្តាំ

តួសញ្ញាសម្គាល់សម្រាប់ព្យួរលើខ្សែគម្របហោប៉ៅអាវខាងស្តាំធ្វើពីលោហធាតុរាងសំប៉ែតមាននិមិត្តសញ្ញារបស់"រដ្ឋបាលជលផល" មានអង្កត់ផ្ចិត៤៥មិល្លីម៉ែត្រ ភ្ជាប់ដោយបន្ទះស្បែកសម្រាប់ព្យួរនៅហោប៉ៅអាវខាងស្តាំ។

សញ្ញាសម្គាល់សម្រាប់ព្យួរលើខ្សែគម្របហោប៉ៅអាវខាងស្តាំ ប្រើចាប់ពីថ្នាក់មន្ត្រីរដ្ឋបាលជលផលដល់ប្រធានរដ្ឋបាលជលផល សម្រាប់បំពេញបេសកកម្មពាក់ព័ន្ធនឹងការគ្រប់គ្រងវិស័យជលផល បំពេញប្រតិបត្តិការស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផល ចូលរួមសវនាការនៅតុលាការ និងចូលរួមពិធីផ្លូវការផ្សេងៗ។

ក្នុងករណីចាំបាច់ពេលបំពេញប្រតិបត្តិការក្នុងទឹក មន្ត្រីរដ្ឋបាលជលផលអាចមិនប្រើសញ្ញាសម្គាល់សម្រាប់ព្យួរលើខ្សែគម្របហោប៉ៅអាវខាងស្តាំបាន។

គំរូសញ្ញាសម្គាល់របស់មន្ត្រីរដ្ឋបាលជលផល ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៨នៃអនុក្រឹត្យនេះ។

## ជំពូកទី៤
## សញ្ញាសក្តិ

**មាត្រា៨ .-**

សញ្ញាសក្តិរបស់មន្ត្រីរដ្ឋបាលជលផលប្រើសម្រាប់ពាក់លើស្មាទាំងសងខាងធ្វើពីលោហធាតុមានរាងទ្រវែងស្តួចនិងប្រវែង១៣២មិល្លីម៉ែត្រ។ ផ្នែកគល់មានប្រវែង៥៧មិល្លីម៉ែត្រ ផ្នែកចុងមានប្រវែង៤៥មិល្លីម៉ែត្រ និងមានរាងកោងជាមុំទាល។

សញ្ញាសក្តិរបស់មន្ត្រីរដ្ឋបាលជលផលត្រូវបានកំណត់ជា៧ថ្នាក់៖

១- ថ្នាក់ប្រធានរដ្ឋបាលជលផល

សញ្ញាសក្តិរបស់ប្រធានរដ្ឋបាលជលផលមានផ្ទៃពណ៌បៃតងចាស់ មានស៊ុមផ្កាភ្លីពណ៌មាសព័ទ្ធជុំវិញ ទំហំ៨មិល្លីម៉ែត្រ មានចម្លាក់ក្បាច់អង្គរភ្ញីទេស គល់ស៊ុមផ្នែកខាងក្រោមមានទំហំ១២មិល្លីម៉ែត្រ។ ផ្នែកខាងលើមានភ្ជាប់ដោយឡេវរូបព្រះរាជសង្ហារពណ៌មាស មានអង្កត់ផ្ចិតប្រវែង១៦មិល្លីម៉ែត្រ និងនៅពីក្រោមឡេវរូបព្រះរាជសង្ហារប្រវែង២០មិល្លីម៉ែត្រ មាននិមិត្តសញ្ញារដ្ឋបាលជលផលពណ៌មាសកម្ពស់៣១មិល្លីម៉ែត្រ និងទទឹង២៤មិល្លីម៉ែត្រ។ ផ្នែកខាងក្រោមនិមិត្តសញ្ញារដ្ឋបាលជលផលប្រវែង២០មិល្លីម៉ែត្រ មានចម្លាក់ក្បាច់អង្គរភ្ញីទេសកន្ទុយហង្សពណ៌មាសកម្ពស់១៤មិល្លីម៉ែត្រ មានបណ្តោយជាប់ស៊ុមនៅពីក្រោមចម្លាក់ក្បាច់អង្គរភ្ញីទេសកន្ទុយហង្សពណ៌មាស មានខ្សែសយពណ៌មាសចំនួន២ ទំហំ១មិល្លីម៉ែត្រ មានបណ្តោយជាប់ស៊ុម និងចន្លោះខ្សែសយទាំងពីរមានចារឹកអក្សរ"**រដ្ឋបាលជលផល**" ពណ៌មាស។

២- ថ្នាក់អនុប្រធានរដ្ឋបាលជលផល

សញ្ញាសក្តិរបស់អនុប្រធានរដ្ឋបាលជលផល មានផ្ទៃពណ៌បៃតងចាស់ និងស៊ុមផ្កាភ្ញីពណ៌មាសព័ទ្ធជុំវិញ ទំហំ៨មិល្លីម៉ែត្រ មានចម្លាក់ក្បាច់អង្គរភ្ញីទេស គល់ស៊ុមផ្នែកខាងក្រោមមានទំហំ១២មិល្លីម៉ែត្រ។ ផ្នែកខាងលើមានភ្ជាប់ដោយឡេវរូបព្រះរាជសង្ហារពណ៌មាស មានអង្កត់ផ្ចិតប្រវែង១៦មិល្លីម៉ែត្រនិងនៅពីក្រោមឡេវរូបព្រះរាជសង្ហារប្រវែង២០មិល្លីម៉ែត្រ មាននិមិត្តសញ្ញារដ្ឋបាលជលផលពណ៌មាសកម្ពស់៣១មិល្លីម៉ែត្រ និងទទឹង ២៤មិល្លីម៉ែត្រ។ ផ្នែកខាងក្រោមនិមិត្តសញ្ញារដ្ឋបាលជលផលប្រវែង២០មិល្លីម៉ែត្រ មានចម្លាក់ក្បាច់អង្គរភ្ញីទេសកន្ទុយហង្សពណ៌មាសកម្ពស់១៤មិល្លីម៉ែត្រ មានបណ្តោយជាប់ស៊ុមនៅពីក្រោមចម្លាក់ក្បាច់អង្គរភ្ញីទេសកន្ទុយហង្សពណ៌មាស មានខ្សែសយពណ៌មាសចំនួន១ ទំហំ២មិល្លីម៉ែត្រ មានបណ្តោយជាប់ស៊ុម និងចន្លោះខ្សែសយទាំងពីរមានចារឹកអក្សរ"**រដ្ឋបាលជលផល**" ពណ៌មាស។

៣- ថ្នាក់ប្រធាននាយកដ្ឋាននិងនាយកវិទ្យាស្ថាន

សញ្ញាសក្តិរបស់ប្រធាននាយកដ្ឋាននិងនាយកវិទ្យាស្ថានមានផ្ទៃពណ៌បៃតងចាស់និងស៊ុមធ្មេញក្របីពណ៌មាសព័ទ្ធជុំវិញទំហំ៧មិល្លីម៉ែត្រ មានចម្លាក់ក្បាច់អង្គរភ្ញីទេស គល់ស៊ុមផ្នែកខាងក្រោមមានទំហំ១២មិល្លីម៉ែត្រ។ ផ្នែកខាងលើមានភ្ជាប់ដោយឡេវរូបព្រះរាជសង្ហារពណ៌មាស មានអង្កត់ផ្ចិតប្រវែង១៦មិល្លីម៉ែត្រ និងនៅពីក្រោមឡេវរូបព្រះរាជសង្ហារប្រវែង២០មិល្លីម៉ែត្រ មាននិមិត្តសញ្ញារដ្ឋបាលជលផលពណ៌មាសកម្ពស់៣១មិល្លីម៉ែត្រនិងទទឹង២៤មិល្លីម៉ែត្រ។ ផ្នែកខាងក្រោមនិមិត្តសញ្ញារដ្ឋបាលជលផលប្រវែង២មិល្លីម៉ែត្រមានចម្លាក់ក្បាច់អង្គរភ្ញីទេសកន្ទុយហង្សពណ៌មាស មានខ្សែសយពណ៌មាសចំនួន២ ទំហំ១មិល្លីម៉ែត្រមានបណ្តោយជាប់ស៊ុមនិងចន្លោះខ្សែសយមានចារឹកអក្សរ"**រដ្ឋបាលជលផល**" ពណ៌មាស។

៤- ថ្នាក់អនុប្រធាននាយកដ្ឋាន នាយករងវិទ្យាស្ថាន នាយអធិការដ្ឋាន និងប្រធានមន្ទីរ

សញ្ញាសក្តិរបស់អនុប្រធាននាយកដ្ឋាន នាយករងវិទ្យាស្ថាន នាយអធិការដ្ឋាន និងប្រធានមន្ទីរ មានផ្ទៃពណ៌បៃតងចាស់ មានស៊ុមធ្មេញក្របីពណ៌មាសព័ទ្ធជុំវិញទំហំ៧មិល្លីម៉ែត្រ មានចម្លាក់ក្បាច់អង្គរភ្ញីទេស គល់ស៊ុមផ្នែកខាងក្រោម មានទំហំ១២មិល្លីម៉ែត្រ។ ផ្នែកខាងលើមានភ្ជាប់ដោយឡេវរូបព្រះរាជសង្ហារពណ៌មាស មានអង្កត់ផ្ចិតប្រវែង១៦មិល្លីម៉ែត្រនិងនៅពីក្រោមឡេវរូបព្រះរាជសង្ហារប្រវែង២០មិល្លីម៉ែត្រ មាននិមិត្តសញ្ញារដ្ឋបាលជលផលពណ៌មាសកម្ពស់៣១មិល្លីម៉ែត្រនិងទទឹង២៤មិល្លីម៉ែត្រ។ ផ្នែកខាងក្រោមនិមិត្តសញ្ញារដ្ឋបាលជលផលប្រវែង២០មិល្លីម៉ែត្រ មានចម្លាក់ក្បាច់អង្គរភ្ញីទេសកន្ទុយហង្សពណ៌មាស មានខ្សែសយពណ៌មាសចំនួន១ ទំហំ២មិល្លីម៉ែត្រមានបណ្តោយជាប់ស៊ុមនិងនៅចន្លោះខ្សែសយទាំងពីរ មានចារឹកអក្សរ "**រដ្ឋបាលជលផល**" ពណ៌មាស។

៥- ថ្នាក់ប្រធានការិយាល័យថ្នាក់កណ្តាល ប្រធានមជ្ឈមណ្ឌល នាយរងអធិការដ្ឋាន អនុប្រធានមន្ទីរនិងនាយខណ្ឌរដ្ឋបាលជលផល

សញ្ញាសក្តិរបស់ប្រធានការិយាល័យថ្នាក់កណ្តាល ប្រធានមជ្ឈមណ្ឌល នាយរងអធិការដ្ឋាន អនុប្រធានមន្ទីរនិងនាយខណ្ឌរដ្ឋបាលជលផល មានផ្ទៃពណ៌បៃតងចាស់ មានស៊ុមធ្មេញត្រីពណ៌មាសព័ទ្ធជុំវិញទំហំ៦មិល្លីម៉ែត្រ មានចម្លាក់ក្បាច់អង្គរភ្ញីទេស គល់ស៊ុមផ្នែកខាងក្រោមមានទំហំ១២មិល្លីម៉ែត្រ។ ផ្នែកខាងលើមានភ្ជាប់ដោយឡេវរូបព្រះរាជសង្ហារពណ៌មាស មានអង្កត់ផ្ចិតប្រវែង១៦មិល្លីម៉ែត្រ និងនៅពីក្រោមឡេវ មានរូបព្រះរាជសង្ហារប្រវែង២០មិល្លីម៉ែត្រ មាននិមិត្តសញ្ញារដ្ឋបាលជលផលពណ៌មាសកម្ពស់៣១មិល្លីម៉ែត្រនិងទទឹង២៤មិល្លីម៉ែត្រ។ ផ្នែកខាងក្រោមនិមិត្តសញ្ញារដ្ឋបាលជលផលប្រវែង២០មិល្លីម៉ែត្រ មានចម្លាក់ក្បាច់អង្គរភ្ញីទេសកន្ទុយហង្សពណ៌មាស មានខ្សែសយពណ៌ប្រាក់ចំនួន២ ទំហំ១មិល្លីម៉ែត្រ មានបណ្តោយជាប់ស៊ុមនិងនៅចន្លោះខ្សែសយ មានចារឹកអក្សរ "**រដ្ឋបាលជលផល**" ពណ៌មាស។

៦- ថ្នាក់អនុប្រធានការិយាល័យថ្នាក់កណ្តាល អនុប្រធានមជ្ឈមណ្ឌល នាយរងខណ្ឌរដ្ឋបាលជលផល នាយ នាយរងផ្នែករដ្ឋបាលជលផល និងនាយ នាយរងសង្កាត់រដ្ឋបាលជលផល

សញ្ញាសក្តិរបស់អនុប្រធានការិយាល័យថ្នាក់កណ្តាល អនុប្រធានមជ្ឈមណ្ឌល នាយរងខណ្ឌរដ្ឋបាលជលផល នាយ នាយរងផ្នែករដ្ឋបាលជលផល និងនាយ នាយរងសង្កាត់រដ្ឋបាលជលផល មានផ្ទៃពណ៌បៃតងចាស់ មានស៊ុមធ្មេញត្រីពណ៌មាសព័ទ្ធជុំវិញទំហំ៦មិល្លីម៉ែត្រ មានចម្លាក់ក្បាច់អង្គរភ្ញីទេស គល់ស៊ុមផ្នែកខាងក្រោម មានទំហំ១២មិល្លីម៉ែត្រ។ ផ្នែកខាងលើមានភ្ជាប់ដោយឡេវរូបព្រះរាជសង្ហារពណ៌មាស មានអង្កត់ផ្ចិតប្រវែង១៦មិល្លីម៉ែត្រ និងនៅពីក្រោមឡេវរូបព្រះរាជសង្ហារប្រវែង២០មិល្លីម៉ែត្រ មាននិមិត្តសញ្ញារដ្ឋបាលជលផលពណ៌មាសកម្ពស់៣១មិល្លីម៉ែត្រនិងទទឹង២៤មិល្លីម៉ែត្រ។ ផ្នែកខាងក្រោមនិមិត្តសញ្ញារដ្ឋបាលជលផលប្រវែង២០មិល្លីម៉ែត្រ មានចម្លាក់ក្បាច់អង្គរភ្ញីទេសកន្ទុយហង្សពណ៌មាស មានខ្សែសយពណ៌ប្រាក់ចំនួន១ទំហំ២មិល្លីម៉ែត្រ មានបណ្តោយជាប់ស៊ុមនិងនៅចន្លោះខ្សែសយទាំងពីរមានចារឹកអក្សរ"**រដ្ឋបាលជលផល**" ពណ៌មាស។

៧- ថ្នាក់មន្ត្រីរដ្ឋបាលជលផល

សញ្ញាសក្តិរបស់មន្ត្រីរដ្ឋបាលជលផល មានផ្ទៃពណ៌ផ្ទៃមេឃ មានស៊ុមធ្មេញត្រីពណ៌មាសព័ទ្ធជុំវិញទំហំ៦មិល្លីម៉ែត្រ មានចម្លាក់ក្បាច់អង្គរភ្ញីទេស គល់ស៊ុមផ្នែកខាងក្រោមមានទំហំ១២មិល្លីម៉ែត្រ។ ផ្នែកខាងលើ មានភ្ជាប់ដោយឡេវរូបព្រះរាជសង្ហារពណ៌ប្រាក់ មានអង្កត់ផ្ចិតប្រវែង១៦មិល្លីម៉ែត្រនិងនៅពីក្រោមឡេវរូបព្រះរាជសង្ហារប្រវែង២០មិល្លីម៉ែត្រ មាននិមិត្តសញ្ញារដ្ឋបាលជលផលពណ៌ប្រាក់កម្ពស់៣១មិល្លីម៉ែត្រនិងទទឹង២៤មិល្លីម៉ែត្រ។ ផ្នែកខាងក្រោមនិមិត្តសញ្ញារដ្ឋបាលជលផលប្រវែង២០មិល្លីម៉ែត្រ មានចារឹកអក្សរ"**រដ្ឋបាលជលផល**" ពណ៌ប្រាក់។

សញ្ញាសក្តិរបស់មន្ត្រីរដ្ឋបាលជលផល ប្រើសម្រាប់ចូលរួមសវនាការនៅតុលាការ និងចូលរួមពិធីផ្លូវការផ្សេងៗ។

គំរូសញ្ញាសក្តិរបស់មន្ត្រីរដ្ឋបាលជលផលត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៥នៃអនុក្រឹត្យនេះ។

## ជំពូកទី៥
## ការផ្តល់និងប្រើឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ

**មាត្រា៩ .-**

ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិដូចបានកំណត់ក្នុងអនុក្រឹត្យនេះ ត្រូវបានផ្តល់ជូនមន្ត្រីដែលបម្រើការងារនៅរដ្ឋបាលជលផល និងមន្ត្រីរដ្ឋបាលជលផលនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីខេត្តរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងម្នាក់ចំនួន២(ពីរ)សម្រាប់ ដើម្បីប្រើក្នុងរយៈពេល១ឆ្នាំ។

ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីរដ្ឋបាលជលផល ត្រូវបានផ្តល់ជូនដោយប្រើថវិកាជាតិ។

**មាត្រា១០ .-**

ក្នុងពេលបំពេញបេសកកម្ម មន្ត្រីរដ្ឋបាលជលផលដែលស្លៀកពាក់ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិមានសិទ្ធិកាន់កាប់និងប្រើអាវុធស្របតាមច្បាប់ជាធរមាន។ អាវុធដែលមន្ត្រីរដ្ឋបាលជលផលប្រើក្នុងការបំពេញការងារត្រូវមានលិខិតអនុញ្ញាតពីក្រសួងមហាផ្ទៃ។

## ជំពូកទី៦

## ទោសប្បញ្ញត្តិ

**មាត្រា១១ ..**

ជនណាដែលបានក្លែងឯកសណ្ឋាន សញ្ញាសម្គាល់ សញ្ញាសក្តិ ឬក្លែងបន្លំខ្លួនដោយស្លៀកពាក់ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីរដ្ឋបាលដលផល ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

## ជំពូកទី៧

## អន្តរប្បញ្ញត្តិ

**មាត្រា១២ ..**

ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីរដ្ឋបាលដលផលដែលកំពុងប្រើសព្វថ្ងៃ ត្រូវបន្តរហូតដល់មានឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិថ្មីមកជំនួស។

## ជំពូកទី៨

## អវសានប្បញ្ញត្តិ

**មាត្រា១៣ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា១៤ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១៣ រោច ខែ ផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ២ ខែ មេសា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១

នៃអនុក្រឹត្យលេខ..៥៤..អនក្រ.បក.ចុះថ្ងៃទី....២......ខែ...មេសា.........ឆ្នាំ២០១៩...

ស្តីពី"**ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីរដ្ឋបាលជលផល**"

## ១. គំរូសម្លៀកបំពាក់

១.១. អាវការងារបុរសនិងនារី(ដៃខ្លីនិងដៃវែង)

អាវបុរសនិងនារី ប្រើសម្រាប់បំពេញការងារពាក់ព័ន្ធនឹងការងារវិស័យជលផល





១.២. អាវនិងខោបុរសនិងនារី ប្រើសម្រាប់ប្រតិបត្តិការ





១.៣_ អាវ៉ាវី (ដៃខ្លីនិងដៃវែង)

អាវ៉ាវីបុរសនិងនារី ប្រើសម្រាប់ចូលរួមសវនាការតុលាការឬចូលរួមពិធីផ្លូវការផ្សេងៗ



១.៤_ ខោនិងសំពត់នារី

ខោនិងសំពត់នារី ប្រើសម្រាប់បំពេញការងារពាក់ព័ន្ធនឹងការងារវិស័យជលផល ឬចូលរួមសវនាការ តុលាការ ឬចូលរួមពិធីផ្លូវការផ្សេងៗ



## ឧបសម្ព័ន្ធទី២

នៃអនុក្រឹត្យលេខ...៥៤...អនក្រ.បក ចុះថ្ងៃទី.....២.....ខែ...មេសា........ឆ្នាំ២០១៨

ស្ដីពី "**ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីរដ្ឋបាលជលផល**"

### ២- គំរូមួក

មួកកាស្កេតនិងមួកកន្តឹប :

២.១- ថ្នាក់ប្រធានរដ្ឋបាលជលផល





២.២- ថ្នាក់អនុប្រធានរដ្ឋបាលជលផល





២.៣- ថ្នាក់ប្រធាននាយកដ្ឋាននិងនាយកវិទ្យាស្ថាន





២.៤- ថ្នាក់អនុប្រធាននាយកដ្ឋាន នាយករងវិទ្យាស្ថាន នាយកអធិការដ្ឋាន និងប្រធានមន្ទីរ





២.៥- ថ្នាក់ប្រធានការិយាល័យថ្នាក់កណ្តាល ប្រធានមជ្ឈមណ្ឌល នាយរងអធិការដ្ឋាន អនុប្រធានមន្ទីរ និងនាយខណ្ឌរដ្ឋបាលជលផល



២.៦- ថ្នាក់អនុប្រធានការិយាល័យថ្នាក់កណ្តាល អនុប្រធានមជ្ឈមណ្ឌល នាយ នាយរងផ្នែករដ្ឋបាលជលផល និងនាយ នាយរងសង្កាត់រដ្ឋបាលជលផល



២.៧. ថ្នាក់មន្ត្រីរដ្ឋបាលជលផល





# ឧបសម្ព័ន្ធទី៣

នៃអនុក្រឹត្យលេខ...៥៤...អនក្រ.បក ចុះថ្ងៃទី.....២.......ខែ...មេសា........ឆ្នាំ២០១៨.

ស្ដីពី "**ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីរដ្ឋបាលជលផល**"

## ៣- គំរូខ្សែក្រវាត់ ស្បែកជើង និងស្រោមជើង

៣.១- ចំពោះបុរស

ខ្សែក្រវាត់



ស្បែកជើង(កខ្លីនិងកវែង)





ស្រោមជើង



ស្បែកជើងផ្ទាត់

៣.២- ចំពោះនារី

ស្បែកជើង(កែងស្មើនិងកែងចោត)





**ឧបសម្ព័ន្ធទី៤**

នៃអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២ ខែ មេសា ឆ្នាំ២០១៨

ស្តីពី "**ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីរដ្ឋបាលជលផល**"

**៤_ គំរូសញ្ញាសម្គាល់**

៤.១_ និមិត្តសញ្ញារដ្ឋបាលជលផល (ធ្វើពីលោហធាតុ)



៤.២_ និមិត្តសញ្ញារដ្ឋបាលជលផលសម្រាប់ភ្ជាប់ដៃអាវខាងស្តាំ (ធ្វើពីក្រណាត់)




៤.៣_ សញ្ញាសម្គាល់ត្រីគល់រាំងសម្រាប់ភ្ជាប់ដៃអាវខាងឆ្វេង (ធ្វើពីក្រណាត់)



៤.៤_ ស្លាកឈ្មោះ






៤.៥_ សញ្ញាសម្គាល់សម្រាប់ព្យួរលើខ្សែរគម្របហោប៉ៅអាវស្តាំ



## ឧបសម្ព័ន្ធទី៥

នៃអនុក្រឹត្យលេខ...៥៤...អនក្រ.បក.ចុះថ្ងៃទី.....១២......ខែ....មេសា.........ឆ្នាំ២០១៨..

ស្តីពី "**ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីរដ្ឋបាលជលផល**"

### ៥. គំរូសញ្ញាសក្តិ

៥.១. ថ្នាក់ប្រធានរដ្ឋបាលជលផល




៥.២. ថ្នាក់អនុប្រធានរដ្ឋបាលជលផល



៥.៣_ ថ្នាក់ប្រធាននាយកដ្ឋាននិងនាយកវិទ្យាស្ថាន



៥.៤_ ថ្នាក់អនុប្រធាននាយកដ្ឋាន នាយករងវិទ្យាស្ថាន នាយអធិការដ្ឋាន និងប្រធានមន្ទីរ



៥.៥- ថ្នាក់ប្រធានការិយាល័យថ្នាក់កណ្តាល ប្រធានមជ្ឈមណ្ឌល នាយរងអធិការដ្ឋាន អនុប្រធានមន្ទីរ និងនាយខណ្ឌរដ្ឋបាលជលផល




៥.៥- ថ្នាក់អនុប្រធានការិយាល័យថ្នាក់កណ្តាល អនុប្រធានមជ្ឈមណ្ឌល នាយ នាយរងផ្នែករដ្ឋបាលជលផល និងនាយ នាយរងសង្កាត់រដ្ឋបាលជលផល



៥.៧- ថ្នាក់មន្ត្រីរដ្ឋបាលជលផល



**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

លេខ ៤១៤ ប្រក កសក

# ប្រកាស
## ស្តីពី
## នីតិវិធីនៃការចេញលិខិតអនុញ្ញាត និងបទដ្ឋានបច្ចេកទេសនៃការនាំចូល ការនាំចេញ ការនាំឆ្លងកាត់ ការផលិត ការលាយផ្សំ ការវេចខ្ចប់ជាថ្មី ការធ្វើសន្និធិ ការផ្គត់ផ្គង់ចែកចាយ ការលក់ដុំលក់រាយ និងការដឹកជញ្ជូនបសុឱសថ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៦/០០៣ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្មចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្មឲ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ



អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣ ២១៧ ៣២០
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
Phone: (023) 726 128 / 726 129, Fax: (855) 23-217 320

- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្តីពីការដំឡើងនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល ទៅជាអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
- បានឃើញប្រកាសរួមលេខ១០១៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ២០៨ ប្រក.កសក ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៨ ស្តីពីនីតិវិធី និងការតម្រូវបមាណីយសម្រាប់ចុះបញ្ជីបសុឱសថ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១ .-**

ប្រកាសនេះមានគោលបំណងកំណត់នូវនីតិវិធីនៃការចេញលិខិតអនុញ្ញាត និងបទដ្ឋានបច្ចេកទេសនៃការនាំចូល ការនាំចេញ ការនាំឆ្លងកាត់ ការផលិត ការលាយផ្សំ ការវេចខ្ចប់ជាថ្មី ការធ្វើសន្និធិ ការផ្គត់ផ្គង់ចែកចាយ ការលក់ដុំលក់រាយ និងការដឹកជញ្ជូនបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ។

**ប្រការ២ .-**

ប្រកាសនេះមានគោលដៅ៖

- ធានាគុណភាព អនាម័យ សុវត្ថិភាព បមាណីយបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ
- ធានាប្រសិទ្ធភាពនៃការគ្រប់គ្រង ការនាំចូល ការនាំចេញ ការនាំឆ្លងកាត់ ការផលិត ការលាយផ្សំ ការវេចខ្ចប់ជាថ្មី ការធ្វើសន្និធិ ការផ្គត់ផ្គង់ចែកចាយ ការលក់ដុំលក់រាយ និងការដឹកជញ្ជូនបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ
- ការពារសុខភាពសត្វ សុខភាពមនុស្ស និងសុខុមាលភាពសត្វ
- ការពារផលប្រយោជន៍អ្នកប្រើប្រាស់ និងបរិស្ថាន។

**ប្រការ៣ .-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគ្រប់សកម្មភាពពាក់ព័ន្ធនឹងការចេញលិខិតអនុញ្ញាត និងការគ្រប់គ្រង ការនាំចូល ការនាំចេញ ការនាំឆ្លងកាត់ ការផលិត ការលាយផ្សំ ការវេចខ្ចប់ជាថ្មី ការធ្វើសន្និធិ ការផ្គត់ផ្គង់ចែកចាយ ការលក់ដុំលក់រាយ និងការដឹកជញ្ជូនបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ សម្រាប់ធ្វើពាណិជ្ជកម្ម និងការប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## នីតិវិធីនៃការចេញលិខិតអនុញ្ញាត
### ផ្នែកទី១
### ការនាំចូល ការនាំចេញ និងការនាំឆ្លងកាត់

**ប្រការ៤ .-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានបំណងធ្វើការនាំចូល ការនាំចេញ ឬការនាំឆ្លងកាត់បសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតនៅអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ។

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតនាំចូល នាំចេញ និងនាំឆ្លងកាត់បសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ត្រូវបំពេញពាក្យស្នើសុំនិងភ្ជាប់មកជាមួយនូវសំណុំឯកសារត្រឹមត្រូវ ពេញលេញដូចមានក្នុងពាក្យស្នើសុំ។

គំរូពាក្យស្នើសុំលិខិតអនុញ្ញាតនាំចូល នាំចេញ និងនាំឆ្លងកាត់បសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ។

**ប្រការ៥ .-**

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ត្រូវធ្វើការពិនិត្យនិងវាយតម្លៃលើសំណុំឯកសាររបស់អ្នកស្នើសុំ។ ក្នុងករណីពិនិត្យឃើញថា សំណុំឯកសារដែលស្នើសុំនោះពិតជាត្រឹមត្រូវ ពេញលេញស្របតាមនីតិវិធីរួចហើយ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ត្រូវស្នើសុំគោលការណ៍សម្រេចពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ផ្អែកតាមគោលការណ៍អនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ត្រូវចេញលិខិតអនុញ្ញាតនាំចូល នាំចេញ ឬនាំឆ្លងកាត់បសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទជូនអ្នកស្នើសុំ។

ដំណើរការពិនិត្យសម្រេចលើពាក្យស្នើសុំរបស់រូបវន្តបុគ្គល ឬនីតិបុគ្គល មានរយៈពេល៣០(សាមសិប)ថ្ងៃគិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំគ្រប់គ្រាន់ និងត្រឹមត្រូវ។

គំរូលិខិតអនុញ្ញាតនាំចូល នាំចេញ និងនាំឆ្លងកាត់បសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ។

**ប្រការ៦ .-**

លិខិតអនុញ្ញាតនាំចូល នាំចេញ និងនាំឆ្លងកាត់បសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ មានសុពលភាពរយៈពេល១(មួយ)ឆ្នាំ លើកលែងតែមានការដកហូត ឬព្យួរលិខិតអនុញ្ញាតនៅមុនកាលបរិច្ឆេទផុតសុពលភាព។

## ផ្នែកទី២
## ការផលិត ការលាយផ្សំ និងការវេចខ្ចប់ជាថ្មី

**ប្រការ៧ .-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានបំណងធ្វើការផលិត ការលាយផ្សំ ឬការវេចខ្ចប់ជាថ្មីនូវបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតនៅអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ។

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតផលិត លាយផ្សំ និងវេចខ្ចប់ជាថ្មីនូវបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ត្រូវបំពេញពាក្យស្នើសុំនិងភ្ជាប់មកជាមួយនូវសំណុំឯកសារត្រឹមត្រូវ ពេញលេញដូចមានក្នុងពាក្យស្នើសុំ។

គំរូពាក្យស្នើសុំលិខិតអនុញ្ញាតផលិត លាយផ្សំ ឬវេចខ្ចប់ជាថ្មីនូវបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៣ នៃប្រកាសនេះ។

**ប្រការ៨ .-**

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ត្រូវធ្វើការពិនិត្យនិងវាយតម្លៃលើសំណុំឯកសាររបស់អ្នកស្នើសុំ និងចាត់មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វ ដើម្បីចុះពិនិត្យនិងវាយតម្លៃលើទីតាំង និងកិច្ចដំណើរការផលិត លាយផ្សំ ឬវេចខ្ចប់ជាថ្មី។ ក្នុងករណីសំណុំឯកសារដែលស្នើសុំនោះពិតជាត្រឹមត្រូវ ពេញលេញស្របតាមនីតិវិធី និងរបាយការណ៍ជាក់ស្តែងរបស់មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ត្រូវស្នើសុំគោលការណ៍សម្រេចពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ផ្អែកតាមគោលការណ៍អនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ត្រូវចេញលិខិតអនុញ្ញាតផលិត លាយផ្សំ ឬវេចខ្ចប់ជាថ្មីនូវបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទជូនអ្នកស្នើសុំ។

ដំណើរការពិនិត្យ សម្រេចលើពាក្យស្នើសុំរបស់រូបវន្តបុគ្គល ឬនីតិបុគ្គល មានរយៈពេល៤៥(សែសិបប្រាំ)ថ្ងៃ គិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំគ្រប់គ្រាន់ និងត្រឹមត្រូវ។

គំរូលិខិតអនុញ្ញាតផលិត លាយផ្សំ ឬវេចខ្ចប់ជាថ្មីនូវបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៤នៃប្រកាសនេះ។

**ប្រការ៩ .-**

លិខិតអនុញ្ញាតផលិត លាយផ្សំ ឬវេចខ្ចប់ជាថ្មីនូវបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ មានសុពលភាពរយៈពេល៥(ប្រាំ)ឆ្នាំ លើកលែងតែមានការដកហូត ឬព្យួរលិខិតអនុញ្ញាតនៅមុនកាលបរិច្ឆេទផុតសុពលភាព។

រូបវន្តបុគ្គល ឬនីតិបុគ្គលត្រូវស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាតផលិត លាយផ្សំ ឬវេចខ្ចប់ជាថ្មីនូវបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ក្នុងរយៈពេលមិនតិចជាង៦(ប្រាំមួយ)ខែ មុនកាលបរិច្ឆេទផុតសុពលភាព។

## ផ្នែកទី៣
## ការធ្វើសន្និធិ

**ប្រការ១០ .-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានបំណងធ្វើសន្និធិសម្រាប់គោលបំណងផ្គត់ផ្គង់ចែកចាយឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទនៅតាមបណ្តារាជធានី ខេត្ត ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រចុះបញ្ជីឃ្លាំងសន្និធិ នៅអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ។

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលដាក់ពាក្យស្នើសុំវិញ្ញាបនបត្រចុះបញ្ជីឃ្លាំងសន្និធិឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ត្រូវបំពេញពាក្យស្នើសុំដោយភ្ជាប់មកជាមួយនូវសំណុំឯកសារត្រឹមត្រូវ ពេញលេញដូចមានក្នុងពាក្យស្នើសុំស្របតាមនីតិវិធីសម្រាប់ការចុះបញ្ជី។

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វត្រូវចាត់មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វ ដើម្បីចុះពិនិត្យ និងវាយតម្លៃជាមុនលើទីតាំងឃ្លាំងសន្និធិដែលស្នើសុំស្របតាមនីតិវិធីសម្រាប់ការចុះបញ្ជី។

គំរូពាក្យស្នើសុំវិញ្ញាបនបត្រចុះបញ្ជីឃ្លាំងសន្និធិឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទសម្រាប់គោលបំណងផ្គត់ផ្គង់ចែកចាយ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៥ នៃប្រកាសនេះ។

**ប្រការ១១ .-**

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ត្រូវធ្វើការពិនិត្យ និងវាយតម្លៃលើសំណុំឯកសាររបស់អ្នកស្នើសុំ។ ក្នុងករណីសំណុំឯកសារដែលស្នើសុំនោះពិតជាត្រឹមត្រូវ ពេញលេញជាមួយនឹងរបាយការណ៍ពិនិត្យ វាយតម្លៃរបស់មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វមានសមត្ថកិច្ចស្របតាមនីតិវិធីសម្រាប់ការចុះបញ្ជី អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ត្រូវចេញវិញ្ញាបនបត្រចុះបញ្ជីឃ្លាំងសន្និធិឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទជូនអ្នកស្នើសុំ។

ដំណើរការពិនិត្យ សម្រេចលើពាក្យស្នើសុំរបស់រូបវន្តបុគ្គល ឬនីតិបុគ្គល មានរយៈពេល៤៥(សែសិបប្រាំ)ថ្ងៃ គិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំគ្រប់គ្រាន់ និងត្រឹមត្រូវ។

គំរូវិញ្ញាបនបត្រចុះបញ្ជីឃ្លាំងសន្និធិឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទសម្រាប់គោលបំណងផ្គត់ផ្គង់ចែកចាយ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៦ នៃប្រកាសនេះ។

**ប្រការ១២ .-**

វិញ្ញាបនបត្រចុះបញ្ជីឃ្លាំងសន្និធិឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ក្នុងគោលបំណងផ្គត់ផ្គង់ចែកចាយមានសុពលភាពរយៈពេល៥(ប្រាំ)ឆ្នាំ លើកលែងតែមានការដកហូត ឬព្យួរវិញ្ញាបនបត្រ នៅមុនកាលបរិច្ឆេទផុតសុពលភាព។

រូបវន្តបុគ្គល ឬនីតិបុគ្គលត្រូវស្នើសុំជាថ្មីនូវវិញ្ញាបនបត្រចុះបញ្ជីឃ្លាំងសន្និធិឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ក្នុងរយៈពេលមិនតិចជាង៣(បី)ខែ មុនកាលបរិច្ឆេទផុតសុពលភាព។

**ប្រការ១៣ .-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានបំណងធ្វើសន្និធិសម្រាប់គោលបំណងលក់ដុំលក់រាយ បសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទនៅក្នុងរង្វង់រាជធានី ខេត្ត ត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រចុះបញ្ជីឃ្លាំងសន្និធិ នៅការិយាល័យផលិតកម្ម និងបសុព្យាបាលនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តសាមី។

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលដាក់ពាក្យស្នើសុំវិញ្ញាបនបត្រចុះបញ្ជីឃ្លាំងសន្និធិបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ត្រូវបំពេញពាក្យស្នើសុំនិងភ្ជាប់មកជាមួយនូវសំណុំឯកសារត្រឹមត្រូវ ពេញលេញដូចមានក្នុងពាក្យស្នើសុំស្របតាមនីតិវិធីសម្រាប់ការចុះបញ្ជី។

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តសាមី ត្រូវចាត់មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វមានសមត្ថកិច្ចនៃការិយាល័យផលិតកម្ម និងបសុព្យាបាលក្រោមឱវាទ ដើម្បីចុះពិនិត្យវាយតម្លៃជាមុនលើទីតាំងឃ្លាំងសន្និធិដែលស្នើសុំស្របតាមនីតិវិធីសម្រាប់ការចុះបញ្ជី។

គំរូពាក្យស្នើសុំវិញ្ញាបនបត្រចុះបញ្ជីឃ្លាំងសន្និធិបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុ គ្រប់ប្រភេទសម្រាប់គោលបំណងលក់ដុំលក់រាយ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៧ នៃប្រកាសនេះ។

**ប្រការ១៤ .-**

ការិយាល័យផលិតកម្ម និងបសុព្យាបាលរាជធានី ខេត្ត ត្រូវធ្វើការពិនិត្យនិងវាយតម្លៃលើសំណុំឯកសាររបស់អ្នកស្នើសុំ។ ក្នុងករណីសំណុំឯកសារដែលស្នើសុំនោះពិតជាត្រឹមត្រូវ ពេញលេញជាមួយនឹងរបាយការណ៍ពិនិត្យវាយតម្លៃរបស់មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វមានសមត្ថកិច្ច លើទីតាំងឃ្លាំងសន្និធិ ស្របតាមនីតិវិធី ការិយាល័យផលិតកម្ម និងបសុព្យាបាលរាជធានី ខេត្ត ត្រូវស្នើសុំគោលការណ៍សម្រេចពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តសាមី។

ផ្អែកតាមគោលការណ៍អនុញ្ញាតរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត ការិយាល័យផលិតកម្ម និងបសុព្យាបាលរាជធានី ខេត្តសាមីនោះ ត្រូវចេញវិញ្ញាបនបត្រចុះបញ្ជីឃ្លាំងសន្និធិបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ដោយមានចុះទិដ្ឋាការពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត ជូនអ្នកស្នើសុំ។

ដំណើរការពិនិត្យសម្រេចលើពាក្យស្នើសុំរបស់រូបវន្តបុគ្គល ឬនីតិបុគ្គល មានរយៈពេល៤៥(សែសិបប្រាំ)ថ្ងៃ គិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំគ្រប់គ្រាន់ និងត្រឹមត្រូវ។

គំរូវិញ្ញាបនបត្រចុះបញ្ជីឃ្លាំងសន្និធិបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទសម្រាប់គោលបំណងលក់ដុំលក់រាយ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៨ នៃប្រកាសនេះ ។

**ប្រការ១៥ .-**

វិញ្ញាបនបត្រចុះបញ្ជីឃ្លាំងសន្និធិបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ក្នុងគោលបំណងលក់ដុំលក់រាយមានសុពលភាពរយៈពេល៥(ប្រាំ)ឆ្នាំ លើកលែងតែមានការដកហូត ឬព្យួរវិញ្ញាបនបត្រ នៅមុនកាលបរិច្ឆេទផុតសុពលភាព។

រូបវន្តបុគ្គល ឬនីតិបុគ្គលត្រូវស្នើសុំជាថ្មីនូវវិញ្ញាបនបត្រចុះបញ្ជីឃ្លាំងសន្និធិបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ក្នុងរយៈពេលមិនតិចជាង៣(បី)ខែ មុនកាលបរិច្ឆេទផុតសុពលភាព។

## ផ្នែកទី៤
## ការផ្គត់ផ្គង់ចែកចាយ និងការលក់ដុំលក់រាយ

**ប្រការ១៦ .-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានបំណងធ្វើការផ្គត់ផ្គង់ចែកចាយបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ នៅតាមបណ្តារាជធានី ខេត្ត ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយ នៅអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ។

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ត្រូវបំពេញពាក្យស្នើសុំនិងភ្ជាប់មកជាមួយនូវសំណុំឯកសារត្រឹមត្រូវ ពេញលេញដូចមានក្នុងពាក្យស្នើសុំ។

គំរូពាក្យស្នើសុំលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៩ នៃប្រកាសនេះ។

**ប្រការ១៧ .-**

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ត្រូវធ្វើការពិនិត្យវាយតម្លៃលើសំណុំឯកសាររបស់អ្នកស្នើសុំ។ ក្នុងករណីពិនិត្យឃើញថា សំណុំឯកសារដែលស្នើសុំនោះពិតជាត្រឹមត្រូវ ពេញលេញស្របតាមនីតិវិធី អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ត្រូវចេញលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទជូនអ្នកស្នើសុំ។

ដំណើរការពិនិត្យសម្រេចលើពាក្យស្នើសុំរបស់រូបវន្តបុគ្គល ឬនីតិបុគ្គល មានរយៈពេល៤៥(សែសិបប្រាំ)ថ្ងៃ គិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំគ្រប់គ្រាន់ និងត្រឹមត្រូវ។

គំរូលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី១០ នៃប្រកាសនេះ។

**ប្រការ១៨ .-**

លិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ មានសុពលភាពរយៈពេល១(មួយ)ឆ្នាំ លើកលែងតែមានការដកហូត ឬព្យួរលិខិតអនុញ្ញាត នៅមុនកាលបរិច្ឆេទផុតសុពលភាព។

**ប្រការ១៩ .-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានបំណងធ្វើការលក់ដុំលក់រាយបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទក្នុងរង្វង់រាជធានី ខេត្ត ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតលក់ដុំលក់រាយនៅការិយាល័យផលិតកម្ម និងបសុព្យាបាលនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តសាមី។

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតលក់ដុំលក់រាយបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ត្រូវបំពេញពាក្យស្នើសុំនិងភ្ជាប់មកជាមួយនូវសំណុំឯកសារត្រឹមត្រូវ ពេញលេញដូចមានក្នុងពាក្យស្នើសុំ។

គំរូពាក្យស្នើសុំលិខិតអនុញ្ញាតលក់ដុំលក់រាយបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី១១ នៃប្រកាសនេះ។

**ប្រការ២០ .-**

ការិយាល័យផលិតកម្ម និងបសុព្យាបាលនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត ត្រូវធ្វើការពិនិត្យវាយតម្លៃលើសំណុំឯកសាររបស់អ្នកស្នើសុំ។ ក្នុងករណីសំណុំឯកសារដែលស្នើសុំនោះពិតជាត្រឹមត្រូវ ពេញលេញស្របតាមនីតិវិធី ការិយាល័យផលិតកម្ម និងបសុព្យាបាលត្រូវស្នើសុំគោលការណ៍សម្រេចពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តសាមី។

ផ្អែកតាមគោលការណ៍អនុញ្ញាតរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត ការិយាល័យផលិតកម្ម និងបសុព្យាបាលរាជធានី ខេត្តសាមីនោះ ត្រូវចេញលិខិតអនុញ្ញាតលក់ដុំលក់រាយបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ដោយមានចុះទិដ្ឋាការពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត ជូនអ្នកស្នើសុំ។

ដំណើរការពិនិត្យសម្រេចលើពាក្យស្នើសុំរបស់រូបវន្តបុគ្គល ឬនីតិបុគ្គល មានរយៈពេល៣០(សាមសិប)ថ្ងៃគិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំគ្រប់គ្រាន់ និងត្រឹមត្រូវ។

គំរូលិខិតអនុញ្ញាតលក់ដុំលក់រាយបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី១២ នៃប្រកាសនេះ។

**ប្រការ២១ .-**

លិខិតអនុញ្ញាតលក់ដុំលក់រាយបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ មានសុពលភាពរយៈពេល១(មួយ)ឆ្នាំ លើកលែងតែមានការដកហូត ឬព្យួរលិខិតអនុញ្ញាត នៅមុនកាលបរិច្ឆេទផុតសុពលភាព។

## ផ្នែកទី៥
## ភាតព្វកិច្ចបង់កម្រៃសេវាសាធារណៈ

**ប្រការ២២ .-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលស្នើសុំលិខិតអនុញ្ញាត ឬវិញ្ញាបនបត្រ ពាក់ព័ន្ធនឹងការនាំចូល ការនាំចេញ ការនាំឆ្លងកាត់ ការផលិត ការលាយផ្សំ ការវេចខ្ចប់ជាថ្មី ការធ្វើសន្និធិ ការផ្គត់ផ្គង់ចែកចាយ និងការលក់ដុំលក់រាយបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម ឬសមាសធាតុគ្រប់ប្រភេទ មានកាតព្វកិច្ចបង់កម្រៃសេវាសាធារណៈចូលថវិកាជាតិ ដោយអនុលោមតាមប្រកាសអន្តរក្រសួងស្តីពីការផ្តល់សេវាសាធារណៈរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ជំពូកទី៣
## បទដ្ឋានបច្ចេកទេស
### ផ្នែកទី១
### ការនាំចូល និងការនាំចេញ

**ប្រការ២៣ .-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើប្រតិបត្តិការនាំចូល ឬការនាំចេញនូវបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ត្រូវអនុវត្តតាមបទដ្ឋានបច្ចេកទេសដែលជាលក្ខខណ្ឌតម្រូវនីមួយៗដូចខាងក្រោមៈ

១- ត្រូវមានលិខិតអនុញ្ញាតនាំចូល ឬនាំចេញ។

២- ត្រូវមានវិញ្ញាបនបត្រចុះបញ្ជីបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ។

៣- ត្រូវមានវិញ្ញាបនបត្រវិភាគបញ្ជាក់គុណភាពពីប្រទេសប្រភពដើម។

៤- ត្រូវមានបញ្ជីឈ្មោះបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទពីប្រទេសប្រភពដើម សម្រាប់ធ្វើការនាំចូល និងការនាំចេញ។

៥- ត្រូវមានឃ្លាំងសន្និធិបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទដែលបានចុះបញ្ជីដោយអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ។

៦- ត្រូវមានបុគ្គលិកបច្ចេកទេសដែលមានសញ្ញាបត្រវេជ្ជសាស្ត្រសត្វដែលទទួលស្គាល់ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

៧- ត្រូវធានាសុវត្ថិភាពក្នុងការដឹកជញ្ជូនបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទឱ្យស្របតាមលក្ខខណ្ឌតម្រូវ ដូចមានចែងក្នុងប្រការ២៩ នៃប្រកាសនេះ។

៨- ត្រូវភ្ជាប់កិច្ចសន្យាស្តីពីការនាំចូល ឬការនាំចេញ រវាងរូបវន្តបុគ្គល ឬនីតិបុគ្គលនោះ ជាមួយអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ។

៩- ត្រូវធ្វើប្រតិវេទន៍ជូនអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ដើម្បីចាត់មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វមានសមត្ថកិច្ចធ្វើការត្រួតពិនិត្យ។

### ផ្នែកទី២
### ការនាំឆ្លងកាត់

**ប្រការ២៤ .-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើប្រតិបត្តិការនាំឆ្លងកាត់នូវបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ត្រូវអនុវត្តតាមបទដ្ឋានបច្ចេកទេសដែលជាលក្ខខណ្ឌតម្រូវនីមួយៗដូចខាងក្រោមៈ

១- ត្រូវមានលិខិតអនុញ្ញាតនាំឆ្លងកាត់។

២- ត្រូវមានបញ្ជីឈ្មោះ បសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទពីប្រទេសប្រភពដើម សម្រាប់ធ្វើការនាំឆ្លងកាត់។

៣- ត្រូវមានកិច្ចសន្យាស្តីពីការនាំឆ្លងកាត់ រវាងរូបវន្តបុគ្គល ឬនីតិបុគ្គលនោះ ជាមួយអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ។

៤- ត្រូវធានាសុវត្ថិភាពក្នុងការដឹកជញ្ជូនបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទឱ្យស្របតាមលក្ខខណ្ឌតម្រូវ ដូចមានចែងក្នុងប្រការ២៩ នៃប្រកាសនេះ និងត្រូវធានាមិនរបើកសៀលសុវត្ថិភាព។

## ផ្នែកទី៣
## ការផលិត និងការលាយផ្សំ

**ប្រការ២៥ .-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើការផលិត ការលាយផ្សំនូវបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ត្រូវអនុវត្តតាមបទដ្ឋានបច្ចេកទេសដែលជាលក្ខខណ្ឌតម្រូវនីមួយៗដូចខាងក្រោម៖

១- ត្រូវមានលិខិតអនុញ្ញាតផលិត លាយផ្សំនូវបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ។

២- ត្រូវមានវិញ្ញាបនបត្រចុះបញ្ជីបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ។

៣- ត្រូវអនុលោមតាមការតម្រូវបមាណីយដែលបានចុះបញ្ជីបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទនោះ។

៤- ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស ធានានូវគុណភាព និងសុវត្ថិភាព ក្នុងការផលិត និងការលាយផ្សំនូវបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ។

៥- ត្រូវមានបរិយាយប័ណ្ណផលិតផលជាភាសាខ្មែរ ដោយត្រូវបញ្ជាក់ឈ្មោះពាណិជ្ជកម្ម ឈ្មោះទូទៅ លេខបញ្ជិកានៃផលិតផលនោះ និងត្រូវបញ្ជាក់ពីសមាសធាតុនិងកម្រិតផ្សំ កម្រិតនិងរបៀបប្រើ វិធីព្យាបាល ផលប៉ះពាល់ ការហាមប្រើប្រាស់ កាលបរិច្ឆេទផលិតនិងផុតកំណត់ការប្រើប្រាស់បសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទនោះ។

៦- ត្រូវមានឈ្មោះពាណិជ្ជកម្ម ឈ្មោះទូទៅ លេខបញ្ជិកា ប្រភពឬប្រទេសផលិត លេខឡូត៍ កាលបរិច្ឆេទផលិតនិងផុតកំណត់ ការប្រើប្រាស់ជាភាសាខ្មែរនៅលើសំបកវេចខ្ចប់គ្រប់ប្រភេទនៃបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ។

៧- ត្រូវមានគំនូសប្លង់ខ្សែច្រវាក់ផលិតកម្ម និងបញ្ជីឈ្មោះសម្ភារៈ ឧបករណ៍បម្រើការផលិត លាយផ្សំបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ។

៨- ត្រូវមានអង្គការលេខនៃគ្រឹះស្ថានផលិត លាយផ្សំបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ។

៩- ត្រូវមានបុគ្គលិកបច្ចេកទេសដែលមានសញ្ញាបត្រវេជ្ជសាស្ត្រសត្វ ឬបសុឱសថការីដែលទទួលស្គាល់ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬឱសថការីដែលទទួលស្គាល់ពីក្រសួងសុខាភិបាល កម្រិតបរិញ្ញាបត្រឡើងទៅ។

១០- ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ និងការទទួលខុសត្រូវរបស់បុគ្គលិកបច្ចេកទេស ក្នុងគ្រប់សកម្មភាពផលិត លាយផ្សំនូវបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ។

១១- ត្រូវមានបញ្ជីដើម ពាណិជ្ជសញ្ញា សោសញ្ញា ពាណិជ្ជនាម ឬលិខិតផ្ទេរសិទ្ធរបស់ក្រុមហ៊ុនផលិត ប្រសិនបើមាន។

១២-ត្រូវមានផែនការនិងមធ្យោបាយចាំបាច់សម្រាប់គ្រប់គ្រងហានិភ័យនៅកន្លែងផលិត និងការលាយផ្សំនូវបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ។

១៣-គ្រឹះស្ថានផលិត លាយផ្សំបសុឱសថ ត្រូវមានប្រព័ន្ធប្រតិបត្តិការនិងត្រួតពិនិត្យដែលធានាចំពោះគុណភាព ប្រសិទ្ធភាព និងសុវត្ថិភាពបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ។

១៤-ត្រូវធ្វើប្រតិវេទន៍ជូនអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ដើម្បីចាត់មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វមានសមត្ថកិច្ចធ្វើការត្រួតពិនិត្យ។

## ផ្នែកទី៤
## ការវេចខ្ចប់ជាថ្មី

### ប្រការ២៦ .-

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើការវេចខ្ចប់ជាថ្មីនូវបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ត្រូវអនុវត្តតាមបទដ្ឋានបច្ចេកទេសដែលជាលក្ខខណ្ឌតម្រូវនីមួយៗដូចខាងក្រោម៖

១- ត្រូវមានលិខិតអនុញ្ញាតវេចខ្ចប់ជាថ្មីនូវបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ។

២- ត្រូវមានវិញ្ញាបនបត្រចុះបញ្ជីបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ។

៣-ត្រូវអនុលោមតាមការតម្រូវបមាណីយដែលបានចុះបញ្ជីបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទនោះ។

៤-ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស ធានានូវគុណភាព និងសុវត្ថិភាព នៃសំបកវេចខ្ចប់ និងការវេចខ្ចប់ជាថ្មី នូវបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ។

៥-ត្រូវមានបរិយាយប័ណ្ណផលិតផលជាភាសាខ្មែរ ដោយត្រូវបញ្ជាក់ឈ្មោះពាណិជ្ជកម្ម ឈ្មោះទូទៅ លេខបញ្ជិកា ប្រភពដើមនៃផលិតផលនោះ និងត្រូវបញ្ជាក់ពីសមាសធាតុនិងកម្រិតផ្សំ កម្រិតនិងរបៀបប្រើ វិធីព្យាបាល ផលប៉ះពាល់ ការហាមប្រើប្រាស់ កាលបរិច្ឆេទផលិតនិងផុតកំណត់ការប្រើប្រាស់បសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទនោះ។

៦-ត្រូវមានឈ្មោះពាណិជ្ជកម្ម ឈ្មោះទូទៅ លេខបញ្ជិកា ប្រភពឬប្រទេសផលិត លេខឡូត៍ កាលបរិច្ឆេទផលិតនិងផុតកំណត់ ការប្រើប្រាស់ជាភាសាខ្មែរនៅលើសំបកវេចខ្ចប់គ្រប់ប្រភេទនៃបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ។

៧-ត្រូវមានបញ្ជីឈ្មោះសម្ភារៈ ឧបករណ៍បម្រើការវេចខ្ចប់ជាថ្មី នូវបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ។

៨- ត្រូវមានអង្គការលេខនៃគ្រឹះស្ថានសម្រាប់វេចខ្ចប់ជាថ្មីនូវបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ។

៩- ត្រូវមានបុគ្គលិកបច្ចេកទេសដែលមានសញ្ញាបត្រវេជ្ជសាស្ត្រសត្វ ឬសុឱសថការីដែលទទួលស្គាល់ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬឱសថការីដែលទទួលស្គាល់ពីក្រសួងសុខាភិបាល កម្រិតបរិញ្ញាបត្រឡើងទៅ។

១០-ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ និងការទទួលខុសត្រូវរបស់បុគ្គលិកបច្ចេកទេស ក្នុងគ្រប់សកម្មភាពដំណើរការវេចខ្ចប់ជាថ្មី នូវបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ។

១១- ត្រូវមានបញ្ជីដើម ពាណិជ្ជសញ្ញា សេវាសញ្ញា ពាណិជ្ជនាម ឬលិខិតផ្ទេរសិទ្ធរបស់ក្រុមហ៊ុនផលិត ប្រសិនបើមាន។

១២- ត្រូវមានផែនការនិងមធ្យោបាយចាំបាច់សម្រាប់គ្រប់គ្រងហានិភ័យនៅគ្រឹះស្ថានវេចខ្ចប់ជាថ្មីនូវបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ។

១៣-គ្រឹះស្ថានវេចខ្ចប់ជាថ្មីនូវបសុឱសថត្រូវមានប្រព័ន្ធប្រតិបត្តិការ និងត្រួតពិនិត្យដែលធានាចំពោះគុណភាព ប្រសិទ្ធភាព និងសុវត្ថិភាពបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ។

១៤-ត្រូវធ្វើប្រតិវេទន៍ជូនអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ដើម្បីចាត់មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វមានសមត្ថកិច្ចធ្វើការត្រួតពិនិត្យ។

## ផ្នែកទី៥
## ការធ្វើសន្និធិ

**ប្រការ២៧ .-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើសន្និធិបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ត្រូវអនុវត្តតាមបទដ្ឋានបច្ចេកទេសដែលជាលក្ខខណ្ឌតម្រូវនីមួយៗដូចខាងក្រោម៖

១- ត្រូវមានវិញ្ញាបនបត្រចុះបញ្ជីឃ្លាំងសន្និធិ។

២- ត្រូវមានវិញ្ញាបនបត្រចុះបញ្ជីបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ។

៣-ត្រូវមានលិខិតអនុញ្ញាតនាំចូល លិខិតអនុញ្ញាតផលិត លាយផ្សំ ឬវេចខ្ចប់ជាថ្មីនូវបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ។

៤- ត្រូវមានប្រព័ន្ធសុវត្ថិភាពសន្និធិបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទដូចជា វិធានថែរក្សាឃ្លាំង វិធានការពារការលេចជ្រាប វិធានការពារពេលមានអាសន្ន ការរៀបចំតាមយថាប្រភេទ តាមឡូត៍ តាមគំនរ និងវិធានសុវត្ថិភាពចំពោះបសុឱសថដែលហួសសុពលភាព។

៥- ឃ្លាំងសន្និធិត្រូវស្ថិតនៅដាច់ពីកន្លែងស្នាក់នៅ និងការិយាល័យធ្វើការងារ។

៦-ត្រូវមានទូ កំណល់ ប្រព័ន្ធត្រជាក់គ្រប់គ្រាន់សម្រាប់រក្សាសីតុណ្ហភាពក្នុងឃ្លាំងសន្និធិតាមលក្ខណៈបច្ចេកទេស។

៧- ត្រូវមានបុគ្គលិកបច្ចេកទេសប្រចាំការដែលមានសញ្ញាបត្រវេជ្ជសាស្ត្រសត្វ ឬបុគ្គលិកប្រចាំការដែលមានការបណ្តុះបណ្តាលពាក់ព័ន្ធនឹងបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ។

៨- ត្រូវមានសៀវភៅកំណត់ត្រាសម្រាប់គ្រប់ប្រតិបត្តិការដែលពាក់ព័ន្ធបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ដូចមានចែងក្នុងគោលការណ៍ណែនាំស្តីពីការដាក់ឱ្យប្រើប្រាស់និងអនុវត្តសៀវភៅកំណត់ត្រាបសុឱសថនិងចំណីសត្វរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

៩-ត្រូវធ្វើប្រតិវេទន៍ជូនអង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល ដើម្បីចាត់មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វមានសមត្ថកិច្ចធ្វើការត្រួតពិនិត្យ។

## ផ្នែកទី៦
## ការផ្គត់ផ្គង់ចែកចាយ និងការលក់ដុំលក់រាយ

**ប្រការ២៨ .-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើការផ្គត់ផ្គង់ចែកចាយ និងការលក់ដុំលក់រាយនូវបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ត្រូវអនុវត្តតាមបទដ្ឋានបច្ចេកទេសដែលជាលក្ខខណ្ឌតម្រូវនីមួយៗដូចខាងក្រោម៖

១- ត្រូវមានលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយ និងការលក់ដុំលក់រាយ។

២-ត្រូវមានវិញ្ញាបនបត្រចុះបញ្ជីបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ។

៣-ត្រូវមានវិញ្ញាបនបត្របញ្ជាក់ការឆ្លងវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈសម្រាប់អ្នកផ្គត់ផ្គង់ចែកចាយ និងអ្នកលក់ដុំលក់រាយបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ។

៤-ហាមឃាត់ការផ្គត់ផ្គង់ចែកចាយ ឬលក់ដុំលក់រាយបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ដែលពុំបានធ្វើការចុះបញ្ជីឬបានចុះបញ្ជីរួចហើយ តែពុំមានលេខឬលុបលេខបញ្ជិកានៅលើស្លាកសញ្ញាព័ត៌មានឬសំបកវេចខ្ចប់។

៥-ហាមឃាត់ការផ្គត់ផ្គង់ចែកចាយ ឬលក់ដុំលក់រាយបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ដែលបានចុះបញ្ជីស្ថិតក្នុងលក្ខខណ្ឌ ឬលិខិតអនុញ្ញាតឲ្យប្រើប្រាស់សម្រាប់ពិសោធន៍។

៦-ហាមឃាត់ការដាក់តាំងលក់បសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ លាយឡំជាមួយគ្រឿងឧបភោគបរិភោគ និងទំនិញដទៃទៀត។

៧-ហាមលក់បសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ដែលក្លែងក្លាយ គ្មានគុណភាព ខូចគុណភាព ផុតកំណត់ការប្រើប្រាស់ ឬយកទៅព្យាបាលមនុស្ស។

៨-ត្រូវមានទូកញ្ចក់សម្រាប់ដាក់តាំង ទូទឹកកក ឬបន្ទប់ត្រជាក់សម្រាប់ទុកដាក់ដែលរក្សាសីតុណ្ហភាពតាមលក្ខណៈបច្ចេកទេស ដោយអនុលោមតាមបរិយាយប័ណ្ណព័ត៌មាន ឬសេចក្ដីណែនាំស្ដីពីការតាំងលក់បសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ។

## ផ្នែកទី៧
## ការដឹកជញ្ជូន

**ប្រការ២៩ .-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើការដឹកជញ្ជូនបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ត្រូវអនុវត្តតាមបទដ្ឋានបច្ចេកទេសដែលជាលក្ខខណ្ឌតម្រូវនីមួយៗដូចខាងក្រោម៖

១- ត្រូវប្រើមធ្យោបាយដឹកជញ្ជូនដើម្បីធានាសីតុណ្ហភាពអនុលោមតាមបរិយាយប័ណ្ណព័ត៌មាន ឬសេចក្ដីណែនាំអំពីសីតុណ្ហភាព សំណើម ពន្លឺ និងរយៈពេលកំណត់ណាមួយ ដោយធានាមិនឲ្យប៉ះពាល់ដល់គុណភាព និងសុវត្ថិភាពក្នុងការដឹកជញ្ជូន។

២-ត្រូវដឹកជញ្ជូនបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទឲ្យបានត្រឹមត្រូវ ដោយបញ្ចៀសការបាក់បែក ផ្ទុះ ឆាបឆេះ ឆ្លងរាលដាល ឬសាយភាយប៉ះពាល់ដល់សុខភាពសាធារណៈ។

៣-ត្រូវផ្ទុកទៅតាមយថាប្រភេទ ប្រភេទមធ្យោបាយ និងត្រូវមានព័ត៌មានអំពីការប្រុងប្រយ័ត្ន។

៤-ត្រូវប្រើមធ្យោបាយដឹកជញ្ជូន និងសម្ភារប្រើប្រាស់សម្រាប់បែងចែកសន្និធិឱ្យសមស្រប និងអាចការពារទៅនឹងលក្ខខណ្ឌបរិស្ថានខាងក្រៅដែលមិនធ្វើឱ្យប៉ះពាល់ដល់ការវេចខ្ចប់ ការឆ្លងមេរោគ គុណភាព និងសុវត្ថិភាព។

៥-ត្រូវមានវិធានការចាំបាច់នានាសម្រាប់ដោះស្រាយនៅពេលជួបឧបទ្ទវហេតុណាមួយក្នុងអំឡុងពេលដឹកជញ្ជូន និងការលើកដាក់ចេញ ចូលមធ្យោបាយដឹកជញ្ជូន។

៦-ត្រូវមានរបាយការណ៍អំពីការដឹកជញ្ជូន អំពីសកម្មភាព ឬហេតុការណ៍មិនប្រក្រតីណាមួយដែលអាចប៉ះពាល់ដល់គុណភាព សុវត្ថិភាព និងសុខភាពសាធារណៈ។

៧-ត្រូវមានបញ្ជីឈ្មោះបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ដែលបានអនុញ្ញាតឱ្យដឹកជញ្ជូន និងរៀបចំទុកដាក់ទៅតាមប្រភេទចំណាត់ថ្នាក់នីមួយៗ ដើម្បីងាយស្រួលដល់មន្ត្រីរបស់អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាលធ្វើអធិការកិច្ច។

៨-ត្រូវធានាឲ្យមានសុវត្ថិភាពក្នុងកំឡុងពេលផ្ទេរបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ស្របតាមបទដ្ឋានបច្ចេកទេស និងគោលការណ៍ណែនាំ។

៩-ត្រូវដឹកជញ្ជូនបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ តាមគ្រប់មធ្យោបាយដោយធានានូវសំបកវេចខ្ចប់នៃផលិតផល ដែលផលិតពីវត្ថុធាតុ ជាប់មាំល្អ ធន់នឹងធាតុអាកាស មិនបណ្តាលឲ្យប្រែប្រួលលក្ខណៈរូប និងគីមីនៃផលិតផល និងផ្តល់ភាពងាយស្រួលដល់ការធ្វើពាណិជ្ជកម្ម និងការប្រើប្រាស់។

១០-ហាមឃាត់រាល់ការដឹកជញ្ជូនបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ដោយដាក់លាយឡំជាមួយគ្រឿងឧបភោគបរិភោគ និងទំនិញដទៃទៀត។

**ប្រការ៣០ .-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានបំណងធ្វើការដឹកជញ្ជូន ឬចរាចរណ៍បសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុគ្រប់ប្រភេទ ដើម្បីផ្គត់ផ្គង់ចែកចាយក្នុងប្រទេស ត្រូវអនុវត្តតាមបទដ្ឋានបច្ចេកទេសនៃការដឹកជញ្ជូនបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្ម និងសមាសធាតុសមាសធាតុគ្រប់ប្រភេទ ដោយត្រូវភ្ជាប់មកជាមួយលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយស្របតាមនីតិវិធីនៃច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ និងឯកសារពាក់ព័ន្ធដែលកំណត់នូវប្រភេទ បរិមាណ និងទីតាំងឬគ្រឹះស្ថានដែលទទួលយកនូវការផ្គត់ផ្គង់ចែកចាយ ដើម្បីមន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វមានសមត្ថកិច្ចធ្វើការត្រួតពិនិត្យ។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**ប្រការ៣១ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣២ .-**

អគ្គលេខាធិការ អគ្គាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៣កើត ខែ អស្សុជ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ១០ ឆ្នាំ២០១៩

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

វេង សាខុន

**កន្លែងទទួល** :

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៣២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ